# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ កៅ-ស៊ុម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

---

## បញ្ជីរឿង

| *ផ្នែកអក្សរសាស្ត្រ* | | *ទំព័រ* |
|---|---|---|
| ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម . . . | រឿងកុលាបប៉ៃលិន . . . . . . . . . . . . | ១៨១ |
| " " . . . . . | ពង្សាវតារប្រទេសចិន ស្រង់ចេញអំពីគោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . . . | ១៩៤ |
| លោកអាចារ្យ គឹម-អាន . . . . . | រឿងព្រះបាទអសោកមហារាជ (តមក) . . . . | ២០៣ |
| អ្នកឧកញ៉ាចេស្ដាវិនិច្ឆ័យកែវ-ហង្ស | រឿងប្រដៅចិត្ត (ពាក្យកាព្យ) (តមក) . . . . | ២១៦ |
| ចម្លងចេញអំពីច្បាប់សាស្ត្រាស្លឹករឹត | រឿងព្រេងខ្មែរ: រឿងចៅធុងចៅសាញ់ . . . . | ២២៣ |
| *ផ្នែកសាសនា* | | |
| ដំណឹងអំពីក្រសួងធម្មការ . . . | អំពីការតាំងចៅអធិការថ្មី នៅវត្តនានា (ក្នុងខែហ្វេវ្រីយេរ) . . . . . . . . . . . . . | ២៣៦ |
| " " . . . . . . | ពិធីបុណ្យបញ្ចុះសីមានៅវត្តនានា . . . . . . | ២៣៩ |
| ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម . . . | ប្រស្នាធម៌អំពីព្រះនិព្វាន . . . . . . . . . | ២៤១ |

---

ឆ្នាំទី ១៥— លេខ ៤ ប្រចាំខែអាព្រីល ១៩៤៣ ។

ថ្លៃប្រជាវ: ១ ឆ្នាំ ១០ រៀល— ៦ ខែ: ៥ រៀល ។

XVe année, no 4.

# KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Khoun Nibandhamantri NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable KAO-SIM, Surveillant général de l'Ecole Supérieure de Pāli.

## TABLE DES MATIÈRES

### Partie littéraire

| | | Pages |
|---|---|---|
| Khoun Nibandhamantri NHOK-THÈM... | Rœung Kolap-Pailin (Roman khmer). | 181 |
| » » ... | Histoire de la Chine. Extraits de divers documents de l'histoire universelle (suite)............. | 194 |
| Feu l'Achar KIM-ANN.... | Légende de l'Empereur AÇOKA de l'Inde antique (suite).......... | 203 |
| Okhna Chesdavinichay KÈO-HANG..... | Prâdaochet (poème) (suite)......... | 206 |
| | Conte populaire cambodgien inédit : " Chao Thaung Chao Sanh ".... | 223 |

### Partie religieuse

| | | |
|---|---|---|
| Informations du Ministère des Cultes..... | Nominations de nouveaux Chao Atthikar...................... | 236 |
| » » ..... | Cérémonie des Simā dans diverses pagodes...................... | 239 |
| Khoun Nibandhamantri NHOK-THÈM.... | A propos du Nirvāna.............. | 241 |

15e année — N° 4. Avril 1943 — Abonnement: un an 10$00.

# រឿងកុលាបប៉ៃលិន

## វគ្គទី ១

គ្រាកាលព្រះសុរិយទេវបុត្រ ទ្រង់គង់លើវិមានកែវផលិកដែលជារថព្រះទីនាំងទឹមដោយសេះអាជានេយ្យ ១ ពាន់, ទ្រង់បរបែរទក្សិណក្នុងព្រះសិនេរុពេជ គាំងអំពីទិសបូព៌ាយាត្រាសំដៅទៅទិសបស្ចិម តាមចក្រសី នៃសុរិយចក្រវាឡ, លុះដល់កំណត់បត់ព្រះកាយរថចូលបាំងជ្រុងមហាបព្វតា រស្មីព្រះសុរិយាក៏ជ្រៀងជ្រែចូលកាន់សន្ធ្យាក្រឹត, នាវេលានោះជាខាងខ្នើត ១៥ កើត ខែកត្តិកឆ្នាំបចត្វាស័ក ព.ស. ២៤៧០; ព្រះចន្ទ្រទេវបុត្រយាងឡើងគង់លើវិមានប្រាក់ ជាកាយរថព្រះទីនាំង, បរចេញមកពីទិសបូព៌ា ចុះពន្លឺពណ៌ប្រាក់ទៅសព្វផែនពសុធា; ព្រះចន្ទ្រាហាក់ដូចជាមៀងមើលមកយ៉ាងស្រស់ញញឹម ព្រោះចាំទៅលើដំបូលគេហស្ថានមួយនៅខាងលិចផ្សារស្វាយប៉ោ ដែលជាផ្សារលើកទីរួមខេត្តបាត់ដំបង ។

ឯគេហស្ថាននោះ ជាផ្ទះបាស់ប្រក់ក្បឿងដំបូលពីរជាន់, ជញ្ជាំងក្តារ, ក្រាលក្តារ, សសរម្សូល, ទ្វារហាជាងមានរូបចម្លាក់ឈើធ្វើជារូបកហូលេបខែ, នៅខាងក្រោមរូបនេះគេឆ្លាក់ជាអក្សរមូលតូចៗ ថា "សិរី-ពាដ្ឋ" ជាផ្ទះខែបែបបុរាណ ដែលនៅសេសសល់ដល់មកសម័យឥឡូវនេះ ។

ក្នុងវេលាព្រឹកនោះ ពន្លឺរស្មីថ្ងៃផ្លូងប្រទ្រកំពុងចាំងចុះចូលមកតាមបន្ទោះបង្អួច ហើយមានខ្យល់ត្រជាក់ បក់ផាត់ផាយចូលមកយ៉ាងរហើយៗ ល្ហើយត្រសៀកល្មមត្រជាក់ស្រួល, នៅខាងក្នុងគេហស្ថាននោះ មានកូនចង្កៀងប្រេងកាត ១ បង្ក្យរទ័ងជញ្ជាំងគារល្មមតែចុះពន្លឺ ឲ្យមើលមកឃើញបុរសជរាម្នាក់ មានកាយស្គាំងស្គមឥតសាច់ឈាម មានតែស្បែកដណ្ដប់ឆ្អឹង ដេកស្តូកស្តឹងនាកណ្ដាលល្វែងបន្ទប់, នៅក្បែរខាងបុរសជរានេះ មានក្មេងកំលោះម្នាក់ មុខមាត់ស្រស់បស់ អង្គុយចាំបំរើថែរក្សាជម្ងឺរបស់បុរសជរា ដោយកិរិយាប្រកបស្រពោនស្រពាប់ស្រងូតស្រងាត់ ឥតមានរីករាយបន្តិចឡើយ, ដ្បិតខំអត់ងងុយថែទាំជម្ងឺរបស់បុរសជរា ដែលត្រូវជាឪពុកបង្កើតរបស់ខ្លួន អស់វេលា ៣ យប់មកហើយ ។

ឯបុរសដែលមានជម្ងឺជាទម្ងន់ កំពុងដេកស្តូកស្តឹងនៅលើដំណេកនេះឈ្មោះ "ពីម, ត្រកូល សិរីពង្ស" កំពុងតែផ្ដាក់ខ្លួនទៅជាចំណីអាហារនៃរោគជរា យូរៗ គាត់ដកដង្ហើមធំវែងៗ ហើយគាត់ចំបើកភ្នែកក្រឡេកមើលទៅពាសពេញទាំងល្វែងបន្ទប់ដេក ភ្នែកទាំងគូរបស់គាត់សំឡឹងទៅចំមុខក្មេងកំលោះម្នាក់ ដែលអង្គុយនៅក្បែរខាងខ្លួនគាត់ ។ ឯក្មេងកំលោះនេះឈ្មោះ ចៅចិត្រ, ជាកូនបណ្ដូលចិត្តរបស់គាត់ ហើយជាអ្នកទទួលតវង្សត្រកូល "សិរីពង្ស" តទៅអនាគតផង ទើបគាត់ចំញញឹមទាំងក្រៀមក្រំ ប្រឹងនិយាយដោយសូរសំឡេងញ័រៗ

ថា "ចិត្រ កូនមាសថ្លៃឪពុក! យប់យន់ណាស់ហើយ មិនទាន់ទៅដេកទេឬ? ទៅ, កូនទៅដេកទៅ" គាត់មកតឿនបង្ខំឲ្យកូនទៅដេក ក្រែងអត់ងងុយទៅជាឈឺចាប់ ។

ចៅចិត្រគ្រវីក្បាលដោយអាការបដិសេធ ព្រមទាំងមានទឹកមុខប្រែកប ដោយចិត្តអាណិតអាសូរបិតា ទើបនិយាយដំកបទៅវិញថា "ខ្ញុំបាទមិនទាន់ងងុយទេ, លោកឪពុក! ប្រហែលជាលោកឪពុកមិនទាន់ពិសាថ្នាំយោងកម្លាំងទេដឹង? លោកគ្រូពេទ្យបានផ្តាំខ្ញុំបាទថា សូមឲ្យលោកឪពុកពិសាកុំខាន ។

"ថ្នាំឬ កូន! គាត់និយាយតែកន្លំបំពង់ក ទំនងបំអកឲ្យថ្នាំនោះ ព្រោះជាថ្នាំគាត់ដឹងថា ឥតមានគុណវិសេសអ្វីបន្តិចឡើយ ហើយគាត់និយាយថា "ឱ! កូនអើយ ថ្នាំនេះឪពុកបានផឹកមកច្រើនលើកហើយ មិនឃើញមានគុណវិសេសអ្វី ដែលអាចជួយបន្ធូរបន្ថយជម្ងឺឲ្យបានស្រាកស្រាន្តសោះឡើយ, ពេលចំពូកនេះឪពុកស្គាល់ច្បាស់ថាជាពេលប្រែប្រាំកាយ "រក្សាកស្លាប់ មិនរក្សាកស្លាប់" ឬទីអំណាចរបស់ថ្នាំក្នុងខណៈនេះ មិនវិសេសជាងទឹកទន្លេទេ, កូន! ។

ចៅចិត្រមិនទាន់បាននិយាយតបទៅឪពុកវិញ ស្រាប់តែលេចបុរសកណ្តាលអាយុម្នាក់ដើរចូលមកក្នុងបន្ទប់, ហើយដាក់ខ្លួនអង្គុយក្បែរ

ខាងក្អកជម្ងឺ ហើយសួរថា មើលទៅតាថ្ងៃនេះ អាការៈរោគបានធូរស្បើយខ្លះទេ ? ។

"ឱ! ព្រះគ្មា, ព្រះគ្មា! តាចឹមលាន់មាត់ឡើង កាលបានឮលោកគ្រូពេទ្យសួរខ្ញុំដូច្នោះ ហើយគាត់និយាយតទៅទៀតថា "ឱ! លោកគ្រូអើយ, វេលានេះ ភ្នែកខ្ញុំបាទស្រវាំងងងឹតអស់ហើយ សូមអត់ទោសចុះ ខ្ញុំបាទមិនដឹងជាលោកគ្រូអញ្ជើញនៅត្រង់ណាទេ" ។ ឯចៅចិត្រ កាលបើបានឮសំដីឪពុកនិយាយខ្សឹកខ្សួលដូច្នោះ ទឹកភ្នែកក៏ហៀរហូរស្រស្រាក់ ដោយចិត្តអាណិតឪពុកពន់ពេក ហើយក៏សំឡឹងមើលគ្រូពេទ្យ និយាយអង្វរករសុំឲ្យជួយស្រោចស្រង់សង្គ្រោះបិតាឲ្យមានជីវិត តែគ្រូពេទ្យដែលស្ទាត់ជំនាញក្នុងវិធីមើលជម្ងឺ ក៏គ្រវីក្បាលដោយអស់សង្ឃឹម, ខ្សឹបប្រាប់ផិតត្រចៀកចៅចិត្រថា "ធ្ងន់មិនផុតអំពីយប់នេះទេ" ។

តាចឹមនិយាយមួយៗ ទាំងហត់ដង្ហក់ចប្បូមាត់សស្ងាំង ញ័រចំប្រប់ ទំនិយាយទៀតថា "ខ្ញុំបាទគង់មិនមានជីវិតរស់នៅ ទាល់តែបានឃើញពន្លឺព្រះអាទិត្យក្នុងព្រឹកស្អែកនេះទៀតទេ" ខ្ញុំបាទយល់ថា មិនមែនជាការចំឡែកខុសធម្មតាទេ ព្រោះមរណៈធម៌ជាសភាវៈទៀងទាត់ ដែលមនុស្សសត្វទៅត្រូវតែទទួលយក និងជៀសវាងឲ្យផុតពុំបានឡើយ ; ឯវិញ្ញាណនិងកាយខ្ញុំបាទ ឥតមានស្រណោះអាឡោះអាល័យប៉ុន្មានទេ ស្លាប់ហើយត្រូវទៅកើតជាអ្វីក៏តាមយថាកម្មចុះ; ហើយបើរៀបនិយាយផ្ដែផ្ដាំ

ថា "ចិត្រ កូនសំឡាញ់មាសឪពុក! កាលបើឪពុកអស់បុណ្យទៅហើយ ជីវិតអ្នកមុខជា សាក់អណ្តែតឥតបង្គោលជាបង្អែកដូចជាសំណាត់ដែលអណ្តែតកណ្តាលទន្លេដូច្នោះ" ។

ឯចៅចិត្រឮលដើមកនិយាយអ្វីមិនរួចសោះ មានតែទឹកភ្នែកហូរស្រស្រាក់ឱនមុខដប់ក្រាបចុះជិតជើងឪពុក ។ ចំណែកខាងគ្រូពេទ្យក៏ងាកមុខបែរទៅខាងបង្អួច ស្ទើរតែទ្រាំទប់ទឹកភ្នែកពុំបានដែរ ។

តាចឹមនិយាយផ្តាំទាំងហត់ថា ៖ "នែចិត្រ កូនសំឡាញ់ឪពុក! កាលបើឪពុកស្លាប់ទៅហើយ ចូរចាំបណ្តាំឪពុកទុកចុះថា "ធម្មជាតគ្រប់យ៉ាងក្នុងលោកនេះ ដែលមនុស្សលោកសំគាល់ថា ជាការរុងរឿងថ្កុំថ្កានោះ គឺការតាំងខ្លួនឲ្យបានស្តុកស្តម្ភដោយទ្រព្យសម្បត្តិ, ឯការដែលរស់នៅគោកយ៉ាកនោះ អ្នកផងទាំងពួងគេមិនយកភ្នែកមើលទេ ការរស់បែបនេះមិនមែននាំឲ្យបានសុខសប្បាយទេ, ប៉ុន្តែពេលនេះកូនអើយ! ឪពុកនឹងប្រាប់អ្នកឲ្យធ្វើដូចម្តេច ទើបបានសេចក្តីចំរើននោះពុំបានទេ សុំឲ្យគ្រាន់តែរលឹកដល់ពុទ្ធភាសិត ១ បទថា "អត្តា ហិ អត្តនោ នាថោ" "ខ្លួនតែទីពឹងរបស់ខ្លួន" ប៉ុណ្ណោះឲ្យរឿយៗចុះ" ។ ឯគ្រូពេទ្យនិយាយដែរក្នុងខណៈនោះថា "តាកុំកាលអស់សង្ឃឹមហើសពេក រោគរបស់តាដែលធ្ងន់ដូច្នេះ ក៏មិនទាន់ជាអ្វីទេ នៅមានសង្ឃឹមនឹងសះជាឡើងវិញបាន" ។

តាបឹមតបឆ្លើយឲ្យគ្រូពេទ្យថា "សះជាឬ? លោកគ្រូ, គ្មានផ្លូវសះជាទៀតវិញជាប្រាកដ មានតែផ្លូវស្លាប់ ១ មុខ គឺក្នុងព្រឹកស្អែកឬយប់នេះ ឬឥឡូវនេះ ក្នុងពេលណាមួយជាមិនខាន" ។ តាបឹមឈប់និយាយ ១ ស្របក់ ហើយចាប់និយាយតទៅទៀតថា "នែ! ចិត្រកូនសំឡាញ់ឪពុក; ឪពុកទីទាល់ក្រណាស់ គ្មានកេរ្តិ៍មត៌កបន្តិចបន្តួចបំរុងទុកឲ្យកូនឡើយ, ដល់ឪពុកស្លាប់ទៅមានតែសពទនឹងពាក្យបណ្ដាំប៉ុណ្ណោះទុកឲ្យកូន; ឯវិញ្ញាណកូនរបស់ឪពុក ដែលនឹងបានទទួលសេចក្ដីសុខក្សេមក្សាន្តក្នុងលោកខាងមុខនោះ លុះតែកូនប្រតិបត្តិតាមបណ្ដាំរបស់ឪពុកទាំងប៉ុន្មានម៉ាត់នេះ ដែលជាបណ្ដាំចុងក្រោយបំផុតរបស់បិតា; មួយទៀត វិជ្ជាដែលឪពុកទុកដាក់ឲ្យកូនរៀនសូត្រ ដកបពាល់តែត្រឡងជាប់សញ្ញាប័ត្រនោះទុកជាមតិកមានដំឡៃមួយ ឪ! តាំងពីថ្ងៃនេះទៅហើយ ឪពុកអស់បានជួយទំនុកបំរុងកូនតទៅទៀតហើយ" ។

ចៅចិត្រ កាលបើបានស្ដាប់ពាក្យបណ្ដាំរបស់ឪពុកចប់សព្វគ្រប់ហើយ ក៏ស្រក់ទឹកភ្នែកស្រោកៗ ដោយមានចិត្តអាល័យនឹងអាណិតឪពុកជាទីបំផុត ឱនក្បាលទៀបជើងឪពុក ហើយខំនិយាយទាំងខ្សឹកខ្សួលជំរាបឪពុកថា "លោកឪពុក! បណ្ដាំគ្រប់ ៗ ម៉ាត់ខ្ញុំបាទនឹងកត់ត្រាចាំទុកក្នុងចិត្ត និងខំប្រតិបត្តិតាមបណ្ដាំគ្រប់ប្រការ, សូមលោកឪពុក

កុំបីព្រួយបារម្ភឡើយ, ខ្ញុំបាទមានជីវិតរស់នៅដកបណា; ទឹងទំតាំងខ្លួនប្រាណដកល់ដំកើនវង្សត្រកូលឲ្យបានចំរើនដកបនោះ" ។

តអំពីពេលនោះ តាចឹមមានអាការវង្វក់កាន់តែញឹកញាប់ខ្លាំងឡើង មានអាការក្រវល់ក្រវាយទំនងស្លុឈាម ហើយទទំពាប់ទៅកល់ៗ ត្រាមរណសន្រ្តាមកំពុងទន្ទ្រានចូលមកជិតអ្នកជម្ងឺគប់ៗវង្វើម៉ ទើបគាត់ខំប្រឹងនិយាយទៅកាត្រូវពេទ្យដែលមានមេត្តាចិត្តចំពោះខ្លួនដោយសូរសំឡេងខ្សាវៗ ជាទំនងសេចក្តីថា "ពានប្រាសលោកគ្រូ! ខ្ញុំបាទទឹងដាច់ខ្យល់ស្លាប់ក្នុងពីរ–បីនាទីនេះហើយ សូមអរព្រះគុណទឹងសូមជូនបុណ្យលោកគ្រូដែលមានព្រះគុណលើខ្លួនខ្ញុំបាទជាអនេក ដោយបានខំថែទាំរក្សាទាំងចង់ខាតថ្លៃថ្នាំជាច្រើនផង ហើយមិនមានគិតថ្លៃរក្សានឹងថ្លៃថ្នាំបន្តិចឡើយ, ខ្ញុំបាទឥតមានអ្វីតបស្នងសងគុណលោកគ្រូទេ, ឱ! ព្រះគុណអើយ, ត្រចៀកខ្ញុំបាទលេងឮហើយ ឱ! ចិត្តកូន! ពុទ្ធោ អរហំ! ។

ចៅចិត្តឱបឱពុកជាប់ ហាក់ដូចជាមិនព្រមឲ្យវិញ្ញាណក្ខន្ធរបស់គាចឹមរត់ចេញពីរាងកាយទៅបាន តែបើទុកជាចៅចិត្តខំប្រឹងទប់ទល់យ៉ាងណាក៏គង់តែមិនសំរេចដូចបំណង ព្រោះ ជាតិ, ជរា, ព្យាធិ, មរណៈ, (កើត, ចាស់, ឈឺ, ស្លាប់) ជាមគ៌ករបស់សត្វលោក ឥតមានសត្វណាមួយ គេចវេះចៀសរាងឲ្យរួចផុតទៅបានឡើយ អម្បាលដូចយ៉ាងព្រះ-អរហំសម្មាសម្ពុទ្ធម៉េចក៏គង់តែស្តេចចូលបរិនិព្វានមិនខាន ។

នៅទីបំផុតនេះ តាបឹមក៏ធ្លាក់ខ្លួនទៅជាចំណីអាហារមច្ចុរាជ គឺជាប់ឲ្យលុំផុតដង្ហើមក្នុងកណ្ដាប់ដៃរបស់ចៅចិត្រជាកូន តាបឹមក៏ទទួលមរណភាព ក្នុងខណៈដែលដួងចន្ទ្រអស្តង្គតបាត់ពន្លឺរស្មី ព្រមជាមួយគ្នាក្នុងគ្រានោះឯង ។

## ជីវិតរបស់ក្មេងកំព្រា

កាលបានចាត់ចែងធ្វើបុណ្យបូជាសពរួចស្រេចហើយ ទើបចៅចិត្រដឹងខ្លួនច្បាស់លាស់ថា "ឱ! ខ្លួនអញអើយ កណ្តែងកណ្តោចខ្លោចផ្សាតែម្នាក់ឯង ហើយទីពឹងពាក់ទៅពឹងបងប្អូនញាតិសាច់សាលោហិតជិតខាងឯណាក៏គ្មាន ណ្ហើយចុះត្រូវតែតស៊ូនឹងសេចក្តីទុក្ខលំបាកគ្រប់យ៉ាងចុះ តើម្តេចកើតមកជាប្រុសកំព្រាម្តាយឪពុក សមដូចជាប្រសាសន៍លោកឪពុកផ្តាំទុកថា "ចិត្រកូន! កាលបើអស់បុណ្យអំពីឪពុកហើយ ជីវិតរបស់អ្នកដូចសំណាក់ឈើដែលអណ្តែតក្នុងកណ្តាលទន្លេដូច្នោះ" ។

ចៅចិត្រក៏គិតឃើញថា ពិភពលោកទាំងមូលនេះ ធំទូលាយស្រួលសប្បាយមែនសម្រាប់អ្នកដទៃ ៗ តែបែរទៅជាទុក្ខចង្អៀតលំបាកពន់ពេកចំពោះខ្លួនអាគ្នាអញដែលកំព្រាម្តាយឪពុក ទីពឹងបងប្អូនញាតិសាលោហិត ទីពឹងពាក់មុខទៅផ្ញើកោនពឹងពាក់អ្នកឯណា ក៏គេឥតត្រូវការសោះ ព្រោះមនុស្សទាល់ក្រលំបាកដូចជាអាគ្នាអញនេះ គេមិនត្រូវការសេពគប់

ពប់រកឡើយ, ទុកជាសុំការគេធ្វើ ក៏ឥតមានទរណាជួយសង្គ្រោះរកការ ងារឲ្យធ្វើបានឡើយ ឱ ! ខ្ញុំអាត្មាអញអើយ កើតមកកងលោកនេះ លំបាកអ្វីក៏សែនលំបាកប្លែកជាងគេម៉្លេះ ; តែជាកើតមកជាអគ្គបុរសហើយ មិនត្រូវខ្លាចសេចក្ដីទុក្ខព្រួយលំបាកទេ គោងតែតស៊ូទ្រាំសេចក្ដីទុក្ខព្រួយ លំបាកអស់នេះឲ្យឃើញស ខ្មៅទៅចុះ ។

ចៅចិត្រកំពុងតែឈរដញ្ជួងរំពឹងគិត រកការធ្វើតែម្នាក់ឯងយ៉ាង ស្ងាត់ៗ នៅចំពៀងខាងមុខផ្ទះ ក៏ងើបមើលទៅលើឃើញព្រះចន្ទ្រអណ្ដែត ត្រសែតនៅកណ្ដាលពពក បញ្ចាំងពន្លឺរស្មីផ្ទះទៅសព្វទីបរិវេណ មាន ខ្យល់បក់ផាត់មកយ៉ាងត្រជាក់ស្រេង ឮសូរសំឡេងព្រះសង្ឃសូត្រធម៌ នៅវត្តព្រះពិគិឆាកមយ៉ាងច្បាស់លាស់ អណ្ដែតលឿនលយមកតាម បណ្ដោយខ្យល់ លុះចៅចិត្របានឮសូរសព្ទព្រះសង្ឃសូត្រធម៌នោះ ក៏ ជាហេតុនាំជួបឲ្យនឹករលឹកដល់ឪពុក ដែលទើបទទួលអនិច្ចកម្មទៅថ្មីៗមិន ដឹងបើនឹងងាកបែរមុខទៅពឹងពាក់អ្នកឯណា ហើយក៏បែរមុខមើលទៅ កុដិបន្ទប់ ឃើញមានពន្លឺចង្កៀងភ្លឺផ្លុង ៗ នៅទីនោះហើយដែលឪពុក ធ្លាប់មូរថ្នាំស្លឹកសន្ធិពិសាជានិច្ច តែឥឡូវនេះមានតែចៅចិត្រម្នាក់ឯង, ចៅចិត្រគិតអាណិតខ្លួនណាស់ ទឹកនេត្រាក៏ហូរចេញមកស្រក់ដោយ ឥតដឹងខ្លួន ។

ខណៈនោះ ចៅចិត្រក្រឡេកមើលទៅខាងមុខ ស្រាប់តែឃើញមនុស្សម្នាក់ស្លៀកសំពត់សដើរចូលមក ទើបចៅចិត្រក្រោកឡើងស្រែកសួរទៅថា " នរណានុ៎ះ?

" គ្នាឯងទេ, ចៅចិត្រឬអីហ្នឹង? បុរសនោះសួរមកវិញ ។ ចៅចិត្រនឹកស្មានថាប្រហែលគ្រូពេទ្យ ទើបស្រែកអញ្ជើញថា " សូមអញ្ជើញលោកគ្រូ" ។

គ្រូពេទ្យក៏ឈានជើងឡើងជណ្ដើរទៅលើផ្ទះ ហើយដាក់ខ្លួនអង្គុយលើកៅអី តាមសេចក្ដីអញ្ជើញរបស់ម្ចាស់ផ្ទះ ។

" សុខសប្បាយជាទេឬចៅចិត្រ? គ្រូពេទ្យសួរដោយមេត្រីចិត្ត ។

ចៅចិត្រតបថា " បាទប្រាស, ចំណែកខាងរាងកាយសុខសប្បាយជាទេ ប៉ុន្តែចំណែកចិត្តរងកម្មជាបំផុត ឥតសប្បាយមួយពេលឡើយ តាំងអំពីលោកឪពុកអនិច្ចកម្មទៅ; វិញ្ញាណខ្ញុំបាទនេះហាក់ដូចជាងងឹតឈឹងពុំដឹងអ្វីឡើយ ! ។

គ្រូពេទ្យងក់ក្បាលទំនងជឿតាមសំដីចៅចិត្រ ទើបសួរថែមទៀតថា "ចុះសព្វថ្ងៃនេះ បានធ្វើការនៅកន្លែងណាហើយឬនៅឡើយទេ?

ចៅចិត្រនិយាយសើចសោះកក្រោះថា " បាទប្រាស! នៅទំនេរ ខ្ញុំបាទរកការធ្វើមិនទាន់បានទេ, ការងារគ្រប់ផ្នែកហាក់ដូចជាខ្ពស់ជាង

ចំណេះរបស់ខ្ញុំបាទ ដែលបានខំរៀនសូត្រមកដូចជាច្រើនណាស់ តែហាក់ដូចគ្រាន់បើការបានត្រឹមតែមើលសំបុត្រស្នាមបន្តិចបន្តួច, មើលឈ្មោះហាងផ្សេងៗ និងមើលប្រូក្រាមតាមរោងកុន-ល្ខោនប៉ុណ្ណោះ ។

គ្រូពេទ្យនិយាយដោយសេចក្ដីអាណិតយ៉ាងស្មោះត្រង់ថា "ខ្ញុំក៏នឹកអាសូរអ្នកច្រើនណាស់ដែរ! ចិត្រ" ហើយនិយាយទូន្មានថា "ខ្លួនអ្នកជាកូនប្រុសត្រូវតែទល់នឹងវិស័យលោកិយទៅមុខទៀតច្រើនណាស់ បង្អង់ឲ្យខ្ញុំគិតពីរ-បីនាទីមើល ក្រែងខ្ញុំគិតរកឧបាយជួយសង្គ្រោះខ្លួនអ្នកឯងបានខ្លះ" ។

ចៅចិត្រនៅតែស្ងៀម ។ គ្រូពេទ្យផ្ចង់គិតមួយស្របក់ក៏ញញឹមលាន់មាត់ចេញសំដីថា "នឹកឃើញហើយៗ! ខ្ញុំមានឪពុកមាម្នាក់ ជាអ្នកស្ដុកស្ដម្ភគ្រាន់បើ មើលទៅបើលោកជួយធុរៈ មុខជាអ្នកឯងបានការធ្វើមិនខាន តែគោងនឿយហត់បន្តិចមុនដំបូង ។

ចៅចិត្រញញឹមញញែមហើយដំពបទៅគ្រូពេទ្យថា "ខ្ញុំបាទទទួលអត់ធន់សេចក្ដីលំបាកគ្រប់យ៉ាងទាំងអស់ សុំឲ្យមានតែការធ្វើនឹងគេចុះ គ្រាន់នឹងបានចិញ្ចឹមជីវិត កុំឲ្យមានពាក្យគេដំនៀលប៉ុណ្ណោះ ទុកជាដីកដីលើសែនវែកពុនយ៉ាងណាក៏ដោយ ខ្ញុំបាទក៏ស៊ូគ្រធ្វើទាំងអស់" ។

គ្រូពេទ្យមានទឹកមុខរីករាយ ដោយសេចក្ដីពេញចិត្តហើយថា "ខ្ញុំគិតឃាទិច្ចថា អ្នកឯងជាកូនប្រុសអាចទទួលធ្វើការគ្រប់ចំពូកបាន អធ្យា-

ស្រ័យអ្នកឯងគួរសរសើរណាស់, ប៉ុន្តែចៅចិត្រ! ការដែលអ្នកឯងត្រូវធ្វើនោះ, មិនមែននៅក្នុងទីនេះទេ គឺនៅឯស្រុកបប៉ៃលិន ឯណោះ" ។

"បប៉ៃលិនឬទានប្រោស! ចៅចិត្រឆ្លើយផ្ទួនពាក្យ បាត់ទឹកមុខញញឹមរីកពយមួយរំពេច ហើយនិយាយត្អូញត្អែរថា "ទានប្រោស, គេថាស្រុកនោះពាញណាស់ មានតែពួកកូមាកូឡា ទើបនៅត្រារកស៊ីក្នុងទីនោះបាន; ខ្ញុំបាទនឹកក្រែងតែត្រាំទ្រទឹកដីអាកាសនៅទីនោះមិនបានទេដឹង? គ្រូពេទ្យទូន្មានថា "អ្នកឯងនិយាយដូច្នេះក៏ត្រូវដែរ ប៉ុន្តែអ្នកដែលទៅហើយឈឺពាញ់នៅទីនោះ ច្រើនធ្ងន់ប្រហែលមិនរេះរក្សាខ្លួនឲ្យផុតពីជម្ងឺគ្រុនពាញ់; ចុះចំណែកអ្នកឯងក៏បានរៀនសូត្រចេះក្បួនពេទ្យមកខ្លះក៏ល្មមនឹងការពារខ្លួនបាន; មួយវិញទៀតជម្ងឺគ្រុនពាញ់នេះ មិនចំពោះតែជាតិយើងទេ ទុកជាជាតិណាក៏ដោយ ធ្វើទាស់ទំនង់ហើយ មុខជាឈឺពាប់ដូចគ្នាទាំងអស់" គ្រូពេទ្យនិយាយទូន្មានចៅចិត្រឲ្យមានះក្លាហានឡើងហើយពោលតទៅទៀតថា "ឯឪពុកមាខ្ញុំនោះ ពីដើមធ្វើជាមន្ត្រីមួយហៅតាមបណ្ដាសក្តិថា "ហ្លួងតេនសម្បត្តិ" វេលានេះអាយុលោក ៩០ ប៉ុបេឆ្នាំហើយ លោកមានអធ្យាស្រ័យល្អ; ពួកកូឡាកូមានៅទីនោះពប់អានលោកណាស់ កាលពី ២-៣ អាទិត្យមុននេះ លោកមានសំបុត្រ ១ ច្បាប់មកដល់ខ្ញុំ សុំឲ្យរើសរកមនុស្សម្នាក់ទៅធ្វើការលោក ចំពោះរូប

អ្នកឯងមួយនេះខ្ញុំទុកចិត្តណាស់; ដ្បិតការជីកត្បូងនិល គេត្រូវការតែមនុស្សសុចរិតស្មោះត្រង់" ។

ចៅចិត្រនិយាយថា "ការនេះជាការថ្មោនថ្មី ក្នុងជីវិតរបស់ខ្ញុំបាទ" ។ គ្រូពេទ្យថា "គ្រាន់បើជាងនៅទំនេរមិនទាន់មានការអ្វីធ្វើមែនទេ? បើព្រមទទួលខ្ញុំនឹងចាត់បញ្ជូនអ្នកឯងទៅវេលាឆាប់ៗនេះ ដោយខ្ញុំមានសេចក្តីសង្ឃឹមទុកចិត្តថា អ្នកឯងនឹងធ្វើការមុឺនមាត់ជាទីពេញចិត្តគេមិនខាន" ។

ចៅចិត្រលើកដៃសំពះ ហើយក្រាបចុះដោយសេចក្តីគោរពចំពោះគ្រូពេទ្យ លោកក៏សរសេរសំបុត្រ ១ ច្បាប់ឲ្យចៅចិត្រ ហើយលាចុះដើរទៅពីផ្ទះនោះទៅ ។

## វគ្គទី ២

## ការធ្វើដំណើរទៅប៉ៃលិន

លុះចៅចិត្របានទទួលសំបុត្រគ្រូពេទ្យហើយ ក៏ចាត់ចែងសំពត់អាវជាក់ពាក់លិសផ្តៅទីងអីវ៉ាន់សម្រាប់ធ្វើដំណើរទៅរួចស្រេចហើយ ក៏ប្រុះដេកសម្រាកដោយសេចក្តីត្រេកអរដ៏លើសលុប ក្នុងយប់នោះស្ទើរតែដេកមិនលក់ទាល់ភ្លឺ ។ ដល់ម៉ោង ៥ ជិតភ្លឺ នាឡិកាឯផ្សារវិលជាយត្ សូម៉ឺង ៗ យ៉ាងច្បាស់លាស់រហូតដល់ផ្ទះចៅចិត្រ ។ ក្រោកឡើងលុបលាងមុខមាត់រួច ។ (នៅមានត)

ពង្សាវតារចិន (តមក)

វគ្គទី ២

# ឈិននិងហ្សួន

កាលអស់បុណ្យព្រះចៅកជាធិកជវ៉ង-ទី ហើយ កជវង្សចិន ក៏កាន់នៅតមកមិនបានយូរប៉ុន្មាន ដោយហេតុកើតចលាចលខាងក្នុងស្រុកឡើង ហើយពួកហ្វូនក៏រុករានទន្ទ្រានចូលមកនៅទិសខាងជើងស្រុកចិន អាណាចក្រចិនក៏រើបរំជួល រហូតមកដល់មានមេទ័ពពូកែម្នាក់ឈ្មោះលៀវ-ប៉ុង ទើបអាចប្រមូលជាតិចិនឡើងវិញបាន ហើយបណ្តេញពួកមនុស្សព្រៃ គឺពួកហ្វូនឲ្យថយឃ្លាតចេញទៅបាន ។

មុនលៀវ-ប៉ុងឡើងសោយរាជសម្បត្តិនោះ ត្រូវច្បាំងតស៊ូនឹងមេទ័ពចិនម្នាក់ទៀតឈ្មោះហៀង-យូ ។ នោះជាមនុស្សមានលក្ខណៈកាចសាហាវណាស់ដូចសត្វសាហាវ ផ្ទុយគ្នានឹងលក្ខណៈរបស់លៀវ-ប៉ុងដែលជាមនុស្សមានមេត្តាករុណាជាប្រក្រតី ។ សង្គ្រាមគ្នានោះ លៀវ-ប៉ុង, ទន់ក៏ច្បាំងចាញ់ហៀង-យូជាច្រើន តែនៅទីបំផុតត្រឡប់ទៅជាមានជ័យជំនះ ហើយហៀង-យូក៏ស្លាប់ទៅ កាលពីពុទ្ធសករាជ ៣៤២ ។ លុះលៀវ-ប៉ុងមានជ័យជំនះហៀង-យូហើយ ក៏ម៉ឺម្មាស្រុកឡើងទៅការពារខេត្តដែនខាន-ស៊ី ដ្បិតមានពួកហ្វូនរុកចូលមកតាមផ្លូវនោះ ចម្បាំង

គ្រានេះលៀវ-ប៊ុង ក៏មិនមានកំឡាំងល្មមនឹងច្បាំងតស៊ូនឹងពួកហ្វូនបានទេ ស្ទើរតែនឹងអស់សង្ឃឹមទៅហើយ ស្រាប់តែកើតគំនិតលែបខាយឡើង គឺជ្រើសរើសបានស្ត្រីរូបស្រស់ម្នាក់ក្នុងពួកប្រពន្ធចុងរបស់ខ្លួន ធ្វើជាទុយឲ្យទៅមេទ័ពធំរបស់ពួកហ្វូន ជាហេតុធ្វើឲ្យពួកហ្វូនលើកលែងច្បាំងហើយថយទ័ពត្រឡប់ទៅវិញ ក្នុងពុទ្ធសករាជ ៣៤៣ អ្នកមើលប្រវត្តិសាស្ត្រចិន គង់នឹងបានឃើញទៅមុខទៀតថា ការលើកស្ត្រីរូបល្អទៅបំបិនឲ្យសត្រូវ សុំឲ្យឈប់រុករានទន្ទ្រានផែនដីនោះ ជាវិធីដែលចិនចូលចិត្តធ្វើណាស់ ហើយសម្រេចដូចបំណងមកច្រើនលើកច្រើនគ្រា ។

តាំងពីនោះមក លៀវ-ប៊ុងបានប្រកាសតាំងខ្លួនជាព្រះចៅរាជាធិរាជនៃប្រទេសចិន ចាត់ជាបឋមក្សត្ររបស់ពួកហ៊ុនទុកជារាជវង្សសំខាន់មួយ ដែលបានគ្រប់គ្រងផែនដីចិន រហូតមកបានដល់ ៤ សតវត្សរ៍ គឺតាំងពីពុទ្ធសករាជ ៣៤៤ ដល់ពុទ្ធសករាជ ៧៦៣ ក្នុងរជ្ជសម័យនៃរាជវង្សហ៊ុននេះ ទីក្រុងរបស់ចិនជាទីដើមតាំងនៅ ស៊ី-អាន ក្នុងខែត្រចេន-ស៊ី ជាវេលា ២០៧ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៣៤២ ដល់ ៥៤៩ តពីនោះមកផ្លាស់មកតាំងនៅ ឯលោ-យ៉ាំង ប្ដូ ឡុក-អៀង ក្នុងខែត្រហ៊ូ-ណាន ។ ក្សត្ររាជវង្ស លៀវ-ប៊ុង មួយអង្គទៀតទ្រង់ព្រះនាមថា វូ-ទី ដែលទ្រង់បានគ្រប-គ្រងប្រទេសចិនរហូតដល់ពុទ្ធសករាជ ៤៥៦ បានពង្រីកអាណាខេត្តចុះទៅខាងត្បូង ហើយបានច្បាំងឈ្នះទ្វីបសង់នៅទិសខាងកើតទៀតផង ។

នៅក្នុងរវាងព្រះពុទ្ធសករាជ ៣០០ ឆ្នាំនោះ នៅខាងទន្លេស៊ី-កៀង (ជាទន្លេសំខាន់មួយរបស់ចិនភាគខាងត្បូង) ក្នុងខេត្តក្វាង-ទុងនោះ មានអាណាចក្រមួយមានអាណាខេត្តទៅទល់នឹងស្រុកតុងកឹង ឈ្មោះថា អាណាចក្រណានយួយ ប្រជាជនជាជាតិយួន តែពួកវង្សត្រកូលដែលគ្រប់គ្រងជាជាតិចិន ។ ក្នុងពុទ្ធសករាជ ៤៣២ ចិនបានចូលមកយកអាណាចក្រនេះ ហើយយកបានស្រុកកាំង-តាំងដែលជាទីក្រុងរបស់អាណាចក្ររួមចូលទៅក្នុងមហាណាចក្រចិនទៀតផង ។ លុះកន្លង ៣ ឆ្នាំមក ចិនបានលើកទ័ពទៅវាយស្រុកសេឆ្វូនបានទៀត ដែនដីដែលយើងហៅថាប្រទេសចិននោះ វៀរលែងតែយុន-ណាន់មួយចេញ សឹងបានរួមចូលក្នុងគ្រប់គ្រងរបស់មហាណាចក្រចិនទាំងអស់ ។

ក្នុងសម័យដែលស្រុកកាំង-តាំង នឹងស្រុកសេឆ្វូនធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃចិននោះ ជាសម័យប្រែប្រួលយ៉ាងសំខាន់មួយ នៃប្រវត្តិសាស្ត្រចុងបូព៌ាប្រទេស ។ ចូរគិតលមើលចុះថា កាលរវាងពុទ្ធសករាជ ៣០០ ឆ្នាំនោះ អាណាចក្ររបស់ចិនមិនធំសំបើម ដល់ជាក្លាយទៅជាប្រទេសធំបំផុតក្នុងលោក ក្នុងកំណត់វេលា ១០០ ឆ្នាំប៉ុណ្ណោះទេ ។ មួយវិញទៀត ព្រះបាទវូ-ទី ទ្រង់អាចពង្រីកអាណាខេត្តរបស់ចិនរហូតទៅដល់ពាក់កណ្ដាលទ្វីបអាស៊ីគិច្ចូស្ត្រង់ផងនោះ ជារឿងដែលគួរដឹងគួរសរសើរសេចក្ដីអង់អាចរបស់ចិនជាច្រើន ដូចមានរឿងសរសេរតទៅ ។

# រឿងអាមាត្យឆាង-កៀន

ដែនដីដែលហៅថា ពាក់កណ្ដាលទ្វីបអាស៊ីនោះ នៅក្នុងអំណាចពួកហ្វូន យើងបានឃើញពីខាងដើមមកហើយថា ពួកហ្វូនបានក្រកានទន្ទ្រានដែនដីចិនជាច្រើនលើកច្រើនគ្រាមកហើយ ទុកជាចិនបានខំកសាងកំពែងយ៉ាងធំសំបើម ខ្ទប់ច្រកទាស់នឹងជីវិតរបស់មនុស្សព្រៃប្រមាណមិនបានក៏ដោយ ក៏នៅតែមិនអាចការពារភ័យអន្តរាយអំពីពួកហ្វូននោះបានឡើយ ។ ព្រះចៅវូ-ទី ជាព្រះចៅកជាធិពជង្គដំបូង ដែលទ្រង់តាំងព្រះទ័យយ៉ាងមុតមាំ ដើម្បីនឹងធ្វើចម្បាំងតស៊ូនឹងពួកហ្វូនឲ្យជាការដាច់ស្រេច មិនបាច់ការពារឲ្យពួកហ្វូនលើកចូលមក ជិតកំពែងធំដូចមុនៗទៀតឡើយ ទើបព្រះចៅវូ-ទីទ្រង់កំណត់គ្រោងការ នឹងលើកទ័ពទៅច្បាំងនឹងពួកហ្វូនឲ្យដល់ស្រុករបស់ពួកហ្វូនតែម្ដង តែទាស់ដោយហេតុពួកចិនមិនសូវស្គាល់ច្រកផ្លូវនឹងភូមិប្រទេសច្បាស់លាស់ល្អ ទើបទ្រង់ជ្រើសរើសចាត់បញ្ជូនអាមាត្យ ដែលមានសតិបញ្ញាឈ្លាសវៃយ៉ាងចំណាប់ម្នាក់ឈ្មោះឆាង-កៀន ។ បានចេញដំណើរទៅក្នុងឆ្នាំពុទ្ធសករាជ ៤០៥ ដើម្បីពិនិត្យច្រកផ្លូវនិងត្រួតមើលភូមិប្រទេសឲ្យបានស្គាល់ជាក់ច្បាស់ ។ ឆាង-កៀនបានចេញដើរផ្លូវទៅរបៀតខែត្រដែន មុន្គលី, វៃគាន, កំបគារ ទួរគីស្តង់នឹងអាហ្វ៉ាន ក្នុងវេលាកំពុងធ្វើដំណើរទៅតាមផ្លូវ

នោះ ឆាង-គៀន ត្រូវពួកហ្វូនចាប់យកទៅឃុំទុកជាវេលាដល់ ១០ ឆ្នាំ ទើបបានលបលួចរត់ចូលទៅក្នុងខែត្រ ត្រង់ស្រុក-សៀន ដែលជាដែនដីរបស់ពួកយូអេជី ឆាង-គៀនបានចូលជាមិត្រយ៉ាងល្អរបស់ពួកយូ-អេជី ហើយបានជួយពួកយូអេជី ច្បាំងនឹងពួកក្រិកនៅបាកត្រៀនផង ហើយនៅទីបំផុត បានត្រឡប់ចូលមកស្រុកចិនខាងស្រុកទីបេត៍ រាប់តាំងពីវេលាដែលឆាង-គៀនចេញពីស្រុកចិនទៅហើយ ត្រឡប់ចូលមកនេះជាវេលាដល់ ១៤ ឆ្នាំ ហើយបានស្គាល់ស្ទាត់នូវប្រែកផ្លូវគ្រប់ប្រទេសតាមដំបន់អស់នោះ យ៉ាងជាក់ច្បាស់ សមដូចព្រះរាជបំណងរបស់ព្រះចៅវូ-ទី ទើបទ្រង់រៀបចំធ្វើចម្បាំងធំនឹងពួកហ្វូនតែម្តង ។

រឿងដែលពោលមកនេះ សឲ្យឃើញនិស្ស័យដ៏រឹងប៉ឹងនិងបំណងយ៉ាងមាំមួន មិនចេះរសាយរបស់ព្រះចៅវូ-ទី ព្រោះតាមធម្មតានោះ បម្រើដែលទៅធ្វើការបាត់ឥតដំណឹងអស់រយៈ ជាវេលាជាង ១០ ឆ្នាំដូចជាឆាង-គៀននោះ ប្រសិនបើជាអ្នកដទៃវិញ គង់លែងគិតនឹកនាំធ្វើចម្បាំងកំផល់អ្វីតទៅទៀត តែព្រះចៅវូ-ទី ទ្រង់តាំងព្រះទ័យយ៉ាងមុតមាំ ទើបទ្រង់ត្រៀមធ្វើចម្បាំងទាល់តែបាន ។

ឯឆាង-គៀនសោតទៀត គួររាប់ជាមហាមាត្យជាន់ឯកសមជាទីទុកព្រះទ័យរបស់ព្រះមហាក្សត្របាន ព្រោះឆាង-គៀនបានត្រួតពិនិត្យគ្រប់ប្រទេសបានហ្មត់ចត់ល្អណាស់ ថែមទាំងបានលួចរៀនយុទ្ធវិធីនឹងរបៀប

ចាត់ទ័ព របស់ពួកហ្វូនសម្រាប់យកមកបង្ហាត់បង្រៀនទាហានចិនផង ហេតុនេះ ក្នុងឆ្នាំពុទ្ធសករាជ ៤២៤ កងទ័ពចិន ២ កងមានចំនួនមនុស្ស ទាំងសែនលើកចេញទៅពីស្រុកចិន ដោយមានមេទ័ពពូកែៗ ពីរនាក់គឺ ឈ្មោះហ្វូ-កៀវពិងនិងវៃ-ចុងជាអ្នកនាំទ័ព បានច្បាំងវាយរុកលុកលុយ ទន្ទ្រានបំផ្លាញជីវិតជាតិហ្វូនជាចំនួនរាប់ពាន់ៗ ហើយវាយយកបានដែន ដីទូរស្គង់ ៗ គ្រប់ៗ តំបន់ដែលកងទ័ពនេះលើកចូលទៅតែងតែមានជ័យ ជំនះគ្រប់អន្លើ ក្រៅពីទូរស្គង់ កងទ័ពរបស់ព្រះបាទរូ-ទី បានរុកឡើង ទៅទិសខាងកើតឆៀងខាងជើង វាយបានដែនលៀវ-តុងនិងដែនកៅលី កាលពីពុទ្ធសករាជ ៤៣៤ ដោយហេតុនេះ ទើបឃើញថា ព្រះចៅ-វូទី ក្នុងពលវង្សហាននេះ គួរបានទទួលកិត្តិយសថាជាអ្នកបណ្ដាលឲ្យប្រទេស ចិន មានអាណាខេត្តហោងធំទូលាយចេញទៅទៀតយ៉ាងសំបើម ។

លុះអស់បុណ្យព្រះបាទវូ-ទីហើយ សេចក្ដីចំរើនរុងរឿងរបស់ចិនក៏ ថយខ្សោយតិចទៅ ក្នុងឆ្នាំពុទ្ធសករាជ ៤៥៣ លី-កួង-លី ជាមេទ័ព ពូកែបំផុតរបស់ចិនមួយ តែត្រឡប់ជាបរាជ័យពួកហ្វូនទៅវិញ ហើយ ចិនក៏ឈប់ផ្សាយអំណាចតាំងអំពីនោះមក រហូតមកដល់សម័យព្រះបាទ ស៊ុអួនទីដែលគ្រប់គ្រងប្រទេសចិនជាវេលា ២៥ ឆ្នាំ គឺតាំងពីពុទ្ធសក-រាជ ៤៧០ ដល់ ៤៩៤ ចិនត្រឡប់ជាមានកម្លាំងខ្លាំងពូកែឡើងវិញ មាន មេទ័ពពូកែម្នាក់ឈ្មោះឆាន-ហ្វូយធ្វើការបង្ក្រាបពួកហ្វូនបានទៀត ។

គ្រានេះ បណ្ដាប្រទេសទាំងឡាយក្នុងអាស៊ីកណ្ដាល សឹងធ្លាក់ទៅក្នុងអំណាចរបស់ព្រះចៅរាជាធិរាជនៃប្រទេសចិន តាំងពីបុរាណកាលរហូតមកដល់វេលាពួកកិក-ម៉េងមានអំណាច ។

រាជវង្សហាន់បានទំនុកបំរុងកម្លាំងទាហានជាយ៉ាងល្អក្រៃពេក ខាងការត្រួតត្រាស្រុកទេសក៏មានរបៀបល្អឡើង មិនចាញ់របៀបខាងទា-ហានទេ ព្រោះរាជវង្សនេះ បានតាំងរាជអាណាចក្រ ធ្វើឲ្យទីក្រុងជាទីប្រជុំចាត់ការត្រួតត្រាខែត្រក្រៅៗទៅក្នុងប្រទេស ព្រះបាទវូ-ទីមានស្រុកជាចំណុះព្រះអង្គដល់ ១០០ ស្រុក រាប់តែចំពោះស្រុកធំៗ ។ ឯតំ-ណែងក្នុងរាជការនោះ អំពីដើមមកនៅក្នុងដៃរបស់ពួកត្រកូលជាន់ខ្ពស់ទាំងអស់ គោលគឺមនុស្សដែលចូលមកធ្វើរាជការបាន គង់តែជាមនុស្សកើតក្នុងត្រកូលខ្ពស់ៗ ព្រះបាទវូ-ទីជាមហាក្សត្រអង្គដំបូង ដែលទ្រង់ប្រកាសលើកលែងលទ្ធិទំនៀមនេះចេញ ហើយទ្រង់ជ្រើសរើសរកមនុស្សមកធ្វើរាជការអំពីប្រជាជនគ្រប់ជាន់គ្រប់ថ្នាក់ដែលមានចំណេះចេះដឹងល្អ ព្រះអង្គនិងព្រះមហាក្សត្រជាលំដាប់ៗ មកក្នុងព្រះរាជវង្សរបស់ព្រះអង្គសឹងទ្រង់ព្យាយាមបន្ថយអំណាចរបស់ពួកមល្លក្សត្រ ត្រាតែស្រុកផ្សេងៗ មកឡើងផ្ទាល់សម្ដេចព្រះរាជាធិរាជតែមួយព្រះអង្គដោយផ្ដាច់ខាត ព្រះបាទស៊ុអួនទី ទ្រង់ឲ្យកាត់កពួកត្រកូលជាន់ខ្ពស់ជាច្រើននាក់ដែលអួតខ្លួនរឹងទទឹងនឹងព្រះរាជអាជ្ញា ។

## រ៉ុង-ម៉ុងឡើងគ្រងរាជ្យ

របៀបពន្ធការដែលពោលមកនេះ ជាហេតុនាំឲ្យពួកត្រកូលជាន់ខ្ពស់ស្អប់ខ្ពើមរាជវង្សហ័នជាច្រើន ហេតុនេះក្នុងឆ្នាំពុទ្ធសករាជ ៥៥២ សេនាបតីដែលមានចិត្តលោភម្នាក់ឈ្មោះរុង-មុង បានផ្តួលរាមហាក្សត្រចេញពីរាជបល្ល័ង្ក ហើយតាំងខ្លួនឯងជាព្រះរាជាធិរាជឡើង តែរ៉ុង-ម៉ុងធ្វើរបេះបណ្តាលឲ្យកើតចលាចលក្នុងស្រុកឡើងយ៉ាងសំបើម ។ មានមនុស្សមួយពួកហៅថា "ពួកចិញ្ចើមក្រហម" បង្កការចលាចលឡើងក្នុងស្រុកចាន-តុង (ឬសាន់-តុង) ព្រះរាជាធិរាជដែលទើបគ្រងរាជថ្មីមិនអាចកម្រាបប្រាបប្រាមឲ្យស្ងប់ស្ងាប់បាន ហើយពួករាជវង្សចាស់ត្រឡប់ជាមានមានះឡើង មានព្រះអង្គម្ចាស់ក្នុងព្រះរាជវង្សហ័នមួយអង្គព្រះនាម "លៀវ-សៀវ" ជាប្រមុខ ហើយតមកក៏កើតច្បាំងគ្នាឡើងយ៉ាងសាហាវ ពួកក្សត្ររាជវង្សចាស់ មានជ័យជំនះចាប់រ៉ុង-ម៉ុងទៅឃុំទុកក្នុងគុកនៅស្រុកស៊ី-អាន កាលពីពុទ្ធសករាជ ៥៦៦ រាជវង្សដែលទើបនឹងសាបសូន្យទៅមួយគ្រា រវាងវេលា ១៥ ឆ្នាំនោះក៏ត្រឡប់តាំងឡើងជាថ្មីវិញបាន ហើយព្រះអង្គម្ចាស់លៀវ-សៀវ ក៏ឡើងគ្រងរាជសម្បត្តិជាព្រះចៅរាជា-ធិរាជទ្រង់ព្រះនាមព្រះបាទក្វាង-វូទី កាលពីពុទ្ធសករាជ ៥៦៨ ហើយទ្រង់គ្រប់គ្រងប្រទេសចិនរហូតដល់ពុទ្ធសករាជ ៦០០ ។

# ពួកហ្លួនបែកសាមគ្គី

ព្រះមហាក្សត្ររាជវង្សហានត្រឡប់តាំងឡើងវិញបានហើយ តែព្រះមហាក្សត្រអង្គថ្មីត្រូវចាប់ផ្ដើមរៀបរៀងអាណាចក្រជាថ្មីឡើងវិញមួយគ្រាទៀត ទើបព្រះចៅក្វាង-វូទី ទ្រង់ផ្លាស់ទីក្រុងពីស្រុកស៊ី-អាន ទៅតាំងនៅលោយ៉ាង ដែលជាទីតាំងនៅត្រង់ពាក់កណ្ដាល សម្រាប់ជាទីត្រួតត្រាស្រុកឯទៀតៗ បានដោយងាយ ហើយជាទីការពារក្រុងបានចំណាប់តាមផ្លូវយុទ្ធសាស្ត្រផង តអំពីនោះមកទ្រង់ក៏ចាត់ការទ័ពពួកចិញ្ចើមក្រ-ហមឲ្យស្ងប់ទៅជាមុន ទើបចេញទៅប្រាប់ប្រាមស្រុកឯទៀតៗ តទៅនៅទីបំផុតវាយយកស្រុកសេ-ឆួនបានទៀត កាលពីពុទ្ធសករាជ ៥៧៩ ស្រុកចិនទាំងមូលក៏ស្ងប់រាបទាបអស់ទៅ ។ ទើបព្រះចៅក្វាង-វូទីបែរទៅប្រាប់ប្រាមអាណាខេត្តជិតខាងដែលធ្លាប់ជាស្រុកចំណុះចិន មកអំពីដើម តែមកកើតរឿងទទឹងមិនព្រមចំណុះក្នុងខណៈដែលប្រទេសចិនកំពុងមានការចលាចល ។

(នៅមានត)

# រឿងព្រះបាទអសោក

(តមក)

គ្រានោះ មានគហបតីម្នាក់ព្រមទាំងភរិយា ទៅស្វែងរកវត្ថុមានដំ-ថ្លៃដើម្បីចិញ្ចឹមជីវិតនៅទីសមុទ្រ ខណៈកំពុងត្រាច់ទៅ ក៏ភរិយាមានគភ៌ ហើយបានប្រសូតកូនប្រុសមួយនៅទីសមុទ្រនោះ ទើបឲ្យឈ្មោះបុត្រនោះថា “សមុទ្រកុមារ” ។ គ្រាកាលកន្លងមក ១២ ឆ្នាំ គហបតីនោះ ក៏នាំភរិយាចេញពីសមុទ្រ ត្រឡប់មកស្រុកកំណើតវិញ តែត្រូវពួកចោរសមុទ្រទាំង ៥០០ ប្លន់ដណ្ដើមយកទ្រព្យសម្បត្តិហើយក៏សម្លាប់គហបតីនោះទៅ ។ គ្រានោះសមុទ្រកុមារនៅកំព្រាតែម្នាក់ឯងអនាថា ទើបចូលទៅបួសក្នុងព្រះពុទ្ធសាសនា ។ លោកត្រាច់ស្វែងរកអាហារបិណ្ឌបាតគ្រប់ស្រុកតូចស្រុកធំនិគមជនបទរៀងៗ ទៅរហូតដល់មកក្រុងបាដលិបុត្រ លុះឃ្លុំចីវរជាបរិមណ្ឌលតាមសមណកេរហើយ ក៏ចូលទៅក្នុងក្រុង ដើម្បីបិណ្ឌបាត លោកនិមន្តរៀងៗ ទៅស្រាប់តែចូលទៅក្នុងគុកជាទីសុខសម្រាន្តនោះដោយមិនដឹងខ្លួនថាជាមន្ទីរអ្វី លុះឃើញដូច្នោះហើយទើបពោលពាក្យនេះថា “ឱហ្ន៎! មន្ទីរនេះ ពីខាងក្រៅមុខគួរជាទីពេញចិត្តពេក តែខាងក្នុងហាក់ដូចជាស្ថាននរកសុទ្ធសាតសោះ” ។ លុះភិក្ខុនោះនឹងត្រឡប់មកវិញ នាយចណ្ឌគិរិកៈឃាត់មិនឲ្យចេញ ប្រាប់ភិក្ខុនោះថា “ឥឡូវនេះ លោកត្រូវនៅក្នុងទីនេះ គឺត្រូវពិឃាតជីវិតបង់ លោក

មិនត្រូវគេបញ្ចេញទៅណាទេ" ពាក្យពោលតែប៉ុណ្ណោះ ក៏ភិក្ខុនោះប្រែកទ្រហោយំសោយសោកបរិទេវនាការឥតស្រាក បណ្ឌិតកៈឃើញដូច្នោះ ទើបសួរថា "ព្រោះហេតុអ្វីបានជាលោកស្រែកយំបែបដូចជាទារកដូច្នេះ" ។

ភិក្ខុនោះតបថា "អាត្មាមិនមែនយំសោកព្រោះខ្លាចសេចក្ដីស្លាប់ដូច្នេះទេ គឺយំដោយសោកស្ដាយ ដោយការវិនាសបង់នូវសមណធម៌ដែលអាត្មាត្រូវបាន ព្រោះថាអាត្មាទើបនឹងបួសហើយថ្មីៗ មិនទាន់បានសម្រេចមគ្គផលអ្វីនៅឡើយសោះ ។ ការបានអត្តភាពមកជាមនុស្សជាការបានដោយកម្រ ធម៌របស់ព្រះពុទ្ធជាសភាពក្របានជួបប្រសព្វ ព្រោះអាត្មានឹកដល់រឿងនោះហើយបានជាអាត្មាយំស្ដាយ" ។ បណ្ឌិតកៈប្រាប់ថា "តាំងពីយូរមកហើយ ព្រះកជាជាម្ចាស់ដីគេបានព្រះរាជទានពរឲ្យខ្ញុំថា បើមានមនុស្សចូលមកមិនត្រូវឲ្យបញ្ចេញទៅវិញទេ ត្រូវឲ្យប្រហារជីវិតក្នុងកំពែងនេះឯង" ។

ភិក្ខុនោះនិយាយអង្វរថា: "អាត្មាភាពសូមឲ្យអ្នកអាណិតទុកជីវិតអាត្មាបាន ៧ ថ្ងៃសិន ខាងក្រោយពី ៧ ថ្ងៃនោះទៅបើអ្នកចង់សម្លាប់អាត្មាភាពក៏សម្លាប់ចុះ" ។ បណ្ឌិតកៈ ក៏ព្រមអនុញ្ញាតឲ្យតាមសេចក្ដីអង្វរ ។

គ្រានោះ ព្រះបាទអសោកបានទតឃើញនាងស្នំកំពុងបរោតដោយកាមកគជាមួយនឹងព្រះអគ្គម្ចាស់កំឡោះមួយព្រះអង្គ ដែលជាសហាយ

លុះទ្រង់ទស្សនាការដូច្នោះហើយ ក៏ទ្រង់ព្រះពិរោធទើបត្រាស់បង្គាប់ឲ្យនាំទាំងពីរនាក់នោះចូលទៅក្នុងគុកជាទីសុខសម្រាន្ត តែមួយរំពេចនោះ ក៏បណ្ឌិតរិកៈបុកប្រចំទេបគូពានកំផទាំង ២ នាក់នោះ សំពង់ក្បាលនឹងអង្រែដែក លៀនក្អួកក្រឡោតក្រលួងចេញមកខាងក្រៅ ៗ ដោយការឃើញកម្មគួរស្បើងយ៉ាងនេះ កិក្កនោះទើបថ្លែងឧទានថា "អា! ព្រះរាជារបស់ព្រះបរមគ្រូជាម្ចាស់ ព្រះអង្គពេញទៅដោយសេចក្ដីករុណា ទ្រង់ត្រាស់ដោយបញ្ញាពិចារណាឃើញពិតថាៈ រូបកាយមិនមែនជារបស់រឹងប៉ឹងមាំមួនទេ មានសភាពដូចជាពពុះទឹក ។ រូបកាយនេះបែកធ្លាយទៅដោយឆាប់រហ័ស ឥតមានបន្ទបន្ទួយសោះឡើយ ឥឡូវនេះរូបឆោមដ៏ល្អនោះទៅណាទៅហើយ ? ទឹកមុខស្រស់ប្រិមប្រិយ និងឆវីវណ្ណទាំងអស់នោះ ក៏វិនាសសូន្យទៅអស់ហើយ ៗ "ឱអនិច្ចា! ក្នុងរូបនិមិត្តនេះឯងហើយ ដែលជាទីពេញចិត្តនៃពួកជនល្ងង់អប្បឥតប្រាជ្ញា ដែលមានគំនិតយល់ឃ្លាងខុសគន្លងធម៌របស់ព្រះសម្មាសម្ពុទ្ធ អាត្មាអញបានឃើញច្បាស់មែនពិតតាមធម៌របស់ព្រះអង្គនោះហើយ នៅក្នុងផ្ទះនៃទាយពេជ្ឈឃាតនេះ អាត្មាអញនឹងមិនលិចលង់ចុះទៅក្នុងឱឃៈគឺកាមគុណទៀតឡើយ" ៗ

ក្នុងមួយព្រឹកទាំងមូលនោះ កិក្កនោះពិចារណាឃើញត្រង់តាមបរម-ពុទ្ធោវាទដូចខាងលើនេះ លោកបានទំលាយបង់នូវចំណង (សំយោជនៈ)

ទាំងអស់ ហើយបានសម្រេចសោតាបត្តិផល ហេតុដូច្នោះ លោកទំ-ព្យាយាមជាលំដាប់នៃមគ្គទៅ ទើបបានសម្រេចដល់អរហត្តផល ។

ព្រះអរុណរះឡើង ដល់ពេលគ្រប់ ៧ ថ្ងៃកន្លងទៅហើយ ចណ្ឌ-គិកៈទើបនិយាយប្រាប់ភិក្ខុនោះថា "កន្លង ៧ រាត្រីទៅហើយ ថ្ងៃនេះជាថ្ងៃទី ៨ លោកនឹងត្រូវទទួលកម្មវេរានោះហើយ" ។

ភិក្ខុនោះតបថា "រាត្រីរបស់អាត្មាកន្លងទៅផុតហើយ ដួងព្រះអាទិត្យរបស់អាត្មារះឡើងហើយ ពេលជាមង្គលមកដល់ហើយ អ្នកនឹងសម្លាប់អាត្មាក៏ធ្វើតាមប្រាថ្នាចុះ" ។

ចណ្ឌគិកៈ ឃើញហេតុប្លែកអំពីថ្ងៃមុនដូច្នោះ ទើបសួរថា: "សំដីលោកនិយាយថា រាត្រីរបស់អាត្មាកន្លងផុតទៅហើយ ដួងព្រះអាទិត្យរបស់អាត្មារះឡើងហើយ ពេលជាមង្គលមកដល់ហើយ ចូរលោកអធិប្បាយពាក្យទាំងអស់នេះឲ្យសព្វគ្រប់មកមើល" ។

ភិក្ខុនោះតបថា :" អាត្មាភាពស្ថិតនៅក្នុងរាត្រី គឺអវិជ្ជាដែលរុំបិទជិតមិនឲ្យមើលពន្លឺអ្វីឃើញសោះ អកុសលទាំងឡាយនាំចិត្តឲ្យក្រាញរញួក ដែលជាចំណងដ៏មាំគឺសំយោជនក្កិលេសនេះ ក៏អាត្មាភាពបានទំលាយបង់ជ្រះស្រឡះហើយ មិនបានត្រឡប់មករករកអាត្មាវិញទេ ទាំងអស់នុ៎ះបានសេចក្ដីថា: រាត្រីរបស់អាត្មាកន្លងផុតទៅហើយ ចិត្តរបស់អាត្មាផូរផង់

ហើយដោយប្រាជ្ញា បានមើលឃើញច្បាស់នូវលោកទាំងបី ទាំងអសន្ទុះ បានសេចក្តីថា: ដួងព្រះអាទិត្យរបស់អាត្មារះឡើងហើយ ៗ កិច្ចដែលព្រះសម្មាសម្ពុទ្ធធ្វើហើយ ជាកិច្ចដែលអាត្មាបានបំពេញសព្វគ្រប់ហើយដែរ ទាំងអសន្ទុះបានសេចក្តីថា: ពេលជាមង្គលមកដល់ហើយ ៗ ពងកាយនេះក៏រស់នៅមកយូរអង្វែងណាស់ដែរហើយ បើអញសម្លាប់អាត្មាក៏តាមតែចិត្តអញចុះ" ៗ

ចណ្ឌាគីរិក: ជាអ្នកប្រាសចាកសេចក្តីករុណា មានចិត្តរឹងរូសដូចជាសិលាបណ្តាលទោស: ក៏ងអាត្មារឹតតែខ្លាំងឡើង ឥតមានកោតក្រែងផលកម្មទៅអនាគត ក៏លើកខ្ទះធំដាក់លើជើងក្រានភ្លើង ក្នុងខ្ទះធំនោះមានទឹកដ៏ពេញលាយទៅដោយខ្ទាញ់លោហិត,ខួរក្នុងឆ្អឹង លាមក(អាចម៍)ទឹកមូត្រទឹកកំទេចកំញមទាំងឡាយ ក៏ចាប់ភិក្ខុនោះឥតមានមេត្តាបោះទៅក្នុងខ្ទះធំនោះ ស្រែកប្រាប់មនុស្ស អ្នកដុតភ្លើងឲ្យប្រឹងខ្មីឃ្មាតយ៉ាងសម្បើមពីខាងក្រោម ធ្វើយ៉ាងនោះហើយខ្ទះទឹងសម្រាមក៏ឆេះ សន្ធោរសន្ធៅឡើង តែមិនមានចំហាយក្តៅដល់ភិក្ខុនោះសោះ សូម្បីតែបន្តិចបន្តួចក៏គ្មានផង នាយពេជ្ឈឃាតឃើញដូច្នោះក៏ខឹងឃោរឃៅទងអ្នកដុតភ្លើងស្ទុះទៅវាយមួយដំបងហើយដុតភ្លើងដោយដៃខ្លួនឯង ភ្លើងក៏ឆេះសន្ធោរឡើងក្រៃលែងជាងមុន តែមិនមានកំដៅសោះ នាយពេជ្ឈឃាតរឹតតែខឹងខ្លាំង ក៏បោចពេចគ្រឿងទំពុសម្ភារមន្ទីរនោះយកមកដុតលាយនឹងសំពត់

ជាច្រើនផ្ទត់ ភ្លើងក៏ឆេះលើសលុបខ្ទះធំនោះ ប៉ុន្តែទឹកនៅតែត្រជាក់ដដែលដូចមុន ក៏នាយពេជ្ឈឃាតនឹកស្ញើចនឹងហេតុអស្ចារ្យចំឡែកនោះ ក្រឡេកមើលទៅក្នុងខ្ទះ ឃើញភិក្ខុនោះអង្គុយសមាធិលើផ្កាឈូកធំមានត្របកមួយពាន់ស្រទាប់ ខណៈនោះនាយចណ្ឌគិរិកៈ មានសេចក្ដីស្ញប់ស្ញែងចិត្តពន់ពេក ក៏រត់ទៅក្រាបទូលដល់ព្រះរាជាឲ្យទ្រង់យាងមកទតហេតុអស្ចារ្យនោះផង ។

ព្រះរាជាស្ដេចយាងមកព្រមដោយបរិវារជាច្រើនពាន់ទ្រង់ទំលាយកំពែងគុកជាទីសុខសម្រាន្តនោះ ដើម្បីពួកអ្នកនគរទាំងអស់រាប់ដោយកោដិ នាំគ្នាចូលទៅមើលភិក្ខុនោះបានដោយងាយ ។ ពេលនោះភិក្ខុនោះបានប្រាប់ថា: ឥឡូវនេះដល់វេលាដែលលោកគួរនឹងទូន្មានព្រះមហាក្សត្រិយ៍ ឲ្យទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាហើយ ទើបលោកសំដែងឥទ្ធិបាដិហារ្យផ្សេងៗ ច្រើនបែប-យ៉ាង មានបីវដីចវិសុទ្ធស្អាតចេញចាកខ្លួនដែលពេញទៅដោយអាបោធាតុនាកណ្ដាលប្រជុំជនដ៏ច្រើនឲ្យបានឃើញគ្រប់ៗគ្នា លោកហោះទៅកាន់អាកាសវេហាស៍ ហើយសំដែងបាដិហារ្យគ្រប់យ៉ាងធ្វើឲ្យមានចំណែកពាក់កណ្ដាលដងខ្លួនរបស់លោក ខាងលើបង្កើតឡើងជាទឹក ហូរចេញមកឥតស្រាក ចំណែកពាក់កណ្ដាលដងខ្លួនរបស់លោកខាងក្រោម បង្កើតឡើងជាភ្លើងឆេះភ្លឺ

ព្រាលវន្ទាលពណ្ណរាយ ហាក់ដូចជាក្អមួយដ៏ធំ មានរស្មីភ្លឺច្រៀលថ្លាត្រុងរឿងទៅនាកណ្ដាលអាកាសនោះ ។

កាលទ្រង់ទតឃើញភិក្ខុនោះហោះទៅក្នុងវេហាសប្រទេសជាហេតុចំឡែកអស្ចារ្យគួរស្ញែងដូច្នោះ ព្រះរាជាក៏ទ្រង់ទតឆ្ពោះទៅខាងលើ លើកព្រះហស្តឡើងប្រណម្យដោយក្រពុំនៃអញ្ជលីជាទីគោរព ហើយទ្រង់មានព្រះបន្ទូលថា:

“ភិក្ខុនេះ ដូចគ្នានឹងយើងសព្វគ្រប់អទ្វៃ មានរូបកាយជាមនុស្សសាមញ្ញ តែឫទ្ធានុភាពនឹងសេចក្ដីបរិសុទ្ធរបស់លោកចំឡែកអស្ចារ្យលើសក្រុមជនមនុស្សធម្មតា លោកហោះឡើងទៅលើអាកាសវេហាស៍ ហើយសំដែងឲ្យឃើញឫទ្ធដ៏សម្បើមអស្ចារ្យហួសវិស័យនៃសត្វលោក ។ ឥឡូវនេះខ្ញុំមិនទាន់ស្គាល់លោកម្ចាស់ទេ ប៉ុន្តែខ្ញុំសូមជ្រកកោននៅក្នុងឥទ្ធិវិសេសរបស់លោក ធ្វើដូចម្ដេចហ្ន៎? នឹងបានដឹងធម៌ ដែលលោកម្ចាស់សំដែងដល់ខ្ញុំនោះ បើបានដឹងហើយ ខ្ញុំនឹងបានប្រព្រឹត្តតាមដោយកំឡាំងនឹងប្រាជ្ញារបស់ខ្ញុំ(១)” ។

ខណៈនោះ ភិក្ខុបានដឹងច្បាស់ថា ព្រះបាទអសោកជាមហាទាន-បតី ១ ដែលនឹងអាចបានចែកចាយព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធដើម្បីជាប្រយោជន៍ដល់ទេពតានឹងមនុស្សទាំងឡាយ ព្រោះដូច្នោះ

---

១ មហាវង្ស: ព្រះបាទអសោក ទ្រង់ជ្រះថ្លាជាដំបូង នឹងនិគ្រោធសាមណេរ ។

ភិក្ខុនោះទើបថ្វាយវិសជ្ជនា ដល់ព្រះបាទអសោកថា: "ព្រះសម្មាសម្ពុទ្ធព្រះអង្គបានត្រាស់ថា: តថាគតមានករុណាដ៏ធំជាអ្នកកាត់បង់នូវចំណងគឺសំយោជនៈបាន ។ អ្នកដែលប្រព្រឹត្តតាមធម៌ដ៏សមគួរដល់ធម៌ ឈ្មោះថាជាទាសនៃព្រះពុទ្ធក្នុងត្រៃកាល អ្នកនោះទើងបានសម្រេចនូវអមតមហានិព្វាន ។ ព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គឈ្នះដោយខ្លួនឯងហើយញ៉ាំងអ្នកដទៃឲ្យឈ្នះផង ព្រះអង្គបានដល់ត្រើយហើយ ញ៉ាំងអ្នកដទៃឲ្យដល់ត្រើយផង ព្រះអង្គបានដល់នូវទីរលត់ទុក្ខហើយញ៉ាំងអ្នកដទៃឲ្យបានដល់ទីរលត់ទុក្ខផង ។ បពិត្រមហារាជ សូមទ្រង់ជ្រាបថា: ព្រះសម្មាសម្ពុទ្ធបានព្យាករទុកហើយដោយច្បាស់លាស់ទៅក្នុងអនាគតថា ខាងក្រោយអំពីបរិនិព្វានរបស់តថាគតទៅមួយរយឆ្នាំ ទ្រង់នឹងបានសោយរាជ្យក្នុងក្រុងបាដលិបុត្រ មានព្រះនាមថាអសោក ទ្រង់នឹងជាស្តេចចក្រពត្តិជាធម្មិករាជ គ្រប់គ្រងទ្វីបមួយក្នុងទ្វីបទាំងបួន នឹងជាស្តេចប្រកបដោយសច្ចធម៌ បានចែកចាយព្រះសារីរិកធាតុព្រមទាំងបានសាងព្រះស្តូប ៨៤.០០០ សុទ្ធសឹងដ៏មានដម្លៃ ឱមហាបពិត្រ ឥឡូវនេះត្រឡប់ជាមានផលផ្ទុយគ្នាទៅវិញ ព្រះអង្គបានសាងគុកធំនេះ ដែលដូចជាស្ថាននរកសុទ្ធសាធ ទ្រង់បានបំផ្លាញជីវិតកប់ចំនួនដោយពាន់មនុស្ស ។

បពិត្រមហាពជ ឥឡូវនេះ សូមទ្រង់ព្រះពជទានអភ័យឲ្យដល់សត្វលោកទាំងអស់ សូមទ្រង់ប្រព្រឹត្តបំពេញសេចក្តីប្រាថ្នារបស់ព្រះសម្មាសម្ពុទ្ធ សូមទ្រង់ព្រះពជទានអភ័យ ដល់មនុស្សទាំងទេវតាទាំងឡាយ សូមព្រះអង្គធ្វើមេត្តាករុណាចិត្តឲ្យកើតឡើងហើយសូមចែកចាយព្រះសារីរិកធាតុនិងជួយផ្សាយធម៌ពិតធម៌មែនឲ្យចំរើនរុងរឿងធំទូលាយឡើង" ។

ព្រះពជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ មានព្រះហឫទ័យយាងចុះកាន់ធម៌របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រកបដោយប្រសាទសទ្ធាជ្រះថ្លាទ្រង់ប្រណម្យអញ្ជលីឡើងគោរពចំពោះព្រះទាសរបស់ព្រះទសពលទើបទ្រង់មានព្រះបន្ទូលថា:

"អំពើរបស់ខ្ញុំពីមុនមក ជាកម្មដ៏អាក្រក់បំផុត សូមឲ្យលោកម្ចាស់ទទួលអតិទោសនៃបាបកម្មរបស់ខ្ញុំនោះពេលនេះ ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ខ្ញុំសូមដល់នូវព្រះធម៌ជាជយមង្គល ដែលព្រះតថាគតត្រាស់សំដែងហើយជាទីពឹងទីរលឹកហើយ[១] ចាប់ដើមតាំងតែពីត្រឹមថ្ងៃនេះទៅ ខ្ញុំនឹងផ្តើមបំពេញតែការកុសល ខ្ញុំនឹងសាងព្រះស្តូបឲ្យបានដេរដាសនៅលើផ្ទៃនៃប្រថពីនេះដើម្បីជាបូជនីយស្ថាន ជាទីរលឹកដល់ព្រះអង្គ" ។

---

១ បាត់សង្ឃសរណៈមួយ មិនឃើញក្នុងច្បាប់ដើម ។

គ្រានោះ កក្កុនោះបានឃើញព្រះកដាស្តេចមានសទ្ធាបរិបូណ៌ ហើយ ក៏ចេញបាកមន្ទីរនៃនាយពេជ្ឈឃាតទៅតាមផ្លូវអាកាស ព្រះមហាក្សត្រិយ៍ក៏ស្តេចចេញមកព្រមផង តែចណ្ឌគិរិកៈ ទូលឃាត់ព្រះអង្គថា: "កាលពីមុន ព្រះអង្គបានព្រះពជទានពរដល់ខ្ញុំព្រះអង្គថា បើអ្នកណាមួយចូលមកក្នុងគុកជាទីសុខសម្រាន្តនេះហើយ នឹងចេញទៅវិញពុំបានជាដាច់ខាត" ។

ព្រះកដាត្រាស់តបថា: "ឯងប្រាថ្នានឹងសម្លាប់យើងផងឬ?"

នាយពេជ្ឈឃាតទូលតបថា "ព្រះករុណាវិសេសទូលព្រះបង្គំជាខ្ញុំប្រាថ្នានឹងសម្លាប់ព្រះអង្គផង" ។

ព្រះមហាក្សត្រិយ៍ត្រាស់សួរថា "យើងទាំងពីរនាក់នេះ អ្នកណាចូលមកក្នុងទីនេះមុនគេ" ។

នាយពេជ្ឈឃាតក្រាបទូលថា "គឺខ្ញុំព្រះអង្គហ្នឹងឯងដែលជាអ្នកចូលមកមុនគេ" ។

ព្រះកដាត្រាស់ថា "អើបើឯងចូលមកមុន ត្រូវតែអញសម្លាប់ឯងមុន" ។

ខណៈនោះ ព្រះមហាក្សត្រិយ៍ទើបត្រាស់ឲ្យហៅកងបរិវារមកឲ្យចាប់ចណ្ឌគិរិកៈ នាំយកទៅកាន់ទីពិឃាត ចណ្ឌគិរិកៈត្រូវនាយពេជ្ឈឃាត

ឯទៀតរាយផ្កាញ់ផ្កាលជាដំណំ ហើយទើបគេទេសបង្កាត់ភ្លើងដុតចណ្ឌគិរិកៈទាំងរស់ឲ្យឆេះជាធូលីក្នុងទីនោះទៅ ។ ព្រះរាជាទ្រង់ត្រាស់ឲ្យទំលាយគុកជាទីសុះសម្រាន្តនោះហើយ ចាប់ដើមតាំងតែពីត្រឹមនោះមក ទ្រង់ប្រទានអភ័យដល់សត្វលោកទាំងអស់ ។

គ្រានោះ ព្រះបាទអសោកព្រមដោយចតុរង្គិនីសេនា ស្តេចយាងចូលទៅក្នុងក្រុងរាជគ្រឹះ ព្រះអង្គចាត់ឲ្យបើកព្រះស្តូបដែលព្រះបាទអជាតសត្តុរាជបានសាងទុកនោះ ទ្រង់ឲ្យគាស់កកាយយកព្រះសារីរិកធាតុទាំងអស់នោះ ហើយព្រះអង្គឲ្យចែកចាយផ្សាយទៅស្ថានទីផ្សេងៗ តពីនោះមក ទ្រង់ឲ្យសាងព្រះស្តូបមួយធំនៅត្រង់កន្លែងដែលនោះ ៗ ចំណែកទីឯទៀតដែលមានបញ្ចុះព្រះសារីរិកធាតុ ទ្រង់ក៏ឲ្យគាស់កកាយយកជាលំដាប់មក នៅកន្លែងទី ២ ទី ៣ ។ល។ ទី ៧ ព្រះអង្គយកព្រះសារីរិកធាតុពីទីនោះៗ ទាំងអស់ដូចគ្នា តមកស្តេចយាងចូលទៅក្នុងស្រុករាមគ្រាមដែលជាទីសំណាក់អាស្រ័យនៃស្តេចនាគឈ្មោះសាគរៈ ដោយមានព្រះបំណងនឹងយកព្រះសារីរិកធាតុក្នុងទីនោះទៀត ។

គ្រានោះ ស្តេចនាគបានសំដែងកាយឲ្យឃើញប្រាកដឡើងហើយ ទូលអញ្ជើញព្រះមហាក្សត្រាធិរាជ ឲ្យស្តេចយាងចូលទៅក្នុងពិភពនាគ ហេតុដូច្នោះ ព្រះរាជាស្តេចយាងចុះកាន់ព្រះទីនាំងនាវា ហើយចូលទៅក្នុងបុរីនៃស្តេចនាគ ។

ស្ដេចនាគបានក្រាបទូលព្រះបរមក្សត្រិយ៍ថា: "សូមព្រះរាជតេជះខ្ញុំព្រះអង្គមានប្រាថ្នានឹងរក្សាទុកនៅព្រះសារីរិកធាតុនេះ សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទុកឲ្យខ្ញុំព្រះអង្គ នឹងបានធ្វើសក្ការបូជាព្រះសារីរិកធាតុនេះផង សូមព្រះអង្គស្ដេចអនុគ្រោះកុំបីយកទៅ" ។

ព្រះរាជាទ្រង់ទតឃើញស្ដេចនាគធ្វើសក្ការៈគោរពកប់ភានបូជាដោយគ្រឿងបូជាចំពោះព្រះសារីរិកធាតុពិសេសមួយថ្ងៃ ឃើញថាជាការវិសេសថ្លៃថ្លាជាងពួកមនុស្សទៅទៀត ទើបទ្រង់ឲ្យទុកព្រះសារីរិកធាតុក្នុងព្រះស្តូបនោះមិនបានយក ហើយស្ដេចយាងត្រឡប់មកព្រះនគរព្រះអង្គវិញ ។

លុះដល់មកព្រះបរមរាជវាំងហើយ ទ្រង់បានឲ្យជាងសាងប្រអប់ដីប្រសើរ ៨៤.០០០ ប្រដាប់ដោយមាសប្រាក់នឹងកែវពិទូរ្យក្នុងប្រអប់មួយៗនោះ ទ្រង់ឲ្យបញ្ចុះព្រះបរមសារីរិកធាតុមួយគ្រាប់ៗ មិនតែប៉ុណ្ណោះសោតទ្រង់ឲ្យសាងក្អម ៨៤.០០០ នឹងត្រប ៨៤.០០០ ដែលជារបស់មានដំឡៃ ហើយនឹងសំពត់កម្ពល ៨៤.០០០ សុទ្ធដ៏មានពណ៌ប្លែកៗ ផ្សេងៗពីគ្នា ដើម្បីនឹងរុំវត្ថុដ៏មានដំឡៃទាំងនោះ ។

ព្រះអង្គទ្រង់ព្រះរាជទានព្រះបរមសារីរិកធាតុឲ្យដល់ពួកយក្ស ក្នុងម្នាក់ៗ មួយគ្រាប់ទ្រង់ត្រាស់បង្គាប់ឲ្យដើរទៅសព្វមណ្ឌលនៃជម្ពូទ្វីប ឲ្យ

យកទៅសាងព្រះស្តូបនៅក្នុងគ្រប់ៗប្រទេស ដែលមានមនុស្សចំនួនមួយកោដិ កាលចាត់ចែងដូចសំដែងមកនេះ យក្សនឹងទេពតាទាំងឡាយក៏បាននាំយកព្រះបរមសារីរិកធាតុទាំងអស់នោះដង្ហែទៅកាន់ទិសទាំងបួន ដើម្បីនឹងសាងព្រះស្តូបទាំងនោះ ។

គ្រានោះ មានយក្សម្នាក់បានទទួលព្រះសារីរិកធាតុមួយគ្រាប់ ហើយ នាំទៅកាន់នគរតក្កសិលា បំណងនឹងសាងព្រះស្តូបមួយនៅក្រុងនោះ តែពួកអ្នកប្រទេសនោះបាននិយាយថា "មនុស្សនៅក្នុងប្រទេសយើងមានចំនួន ៣៦ កោដិ បើដូច្នោះត្រូវអោយប្រអប់ ៣៦ មកយើង" ។

គ្រានោះយក្សនឹងទេពតាក៏ត្រឡប់មកក្រាបទូលសេចក្តីនោះដល់ព្រះមហាក្សត្រិយ៍វិញ ព្រះអង្គមានព្រះដំរិះថា: "មនុស្សទាំងឡាយមានចំនួនច្រើនណាស់ ប្រសិនបើធ្វើតែយ៉ាងនេះព្រះបរមសារីរិកធាតុនឹងមិនបានផ្សាយទូទៅសព្វជម្ពូទីបទាំងមូលទេ បើដូច្នេះ ត្រូវរកឧបាយនឹងបញ្ឈប់ការចែកចាយត្រឹមនេះ" ។ ខណៈនោះ ព្រះរាជាទ្រង់ត្រាស់ឲ្យយក្សត្រឡប់ទៅប្រាប់ដល់មនុស្សទាំងនោះថា "ក្នុងប្រទេសនេះត្រូវបន្ថយមនុស្ស ៣៥ កោដិចេញឲ្យនៅតែត្រឹមមួយកោដិ ដែលនឹងត្រូវបានព្រះបរមសារីរិកធាតុមួយគ្រាប់ប៉ុណ្ណោះ" ។

(នៅមានត)

## ប្រដៅចិត្ត

អ្នកទកញ៉ាចេស្តាវិនិច្ឆ័យ (កែវ-ហង្ស)

(តមក)

អាខូចឃើញមាសប្រាក់អរព្រួច តាំងពិធីរួចលួចគ្មានសល់ អ្នកល្ងង់នៅល្ងើធ្វើស្រងិល ខូចអស់កំណល់ខ្លួនមានគ្រោះ ៗ នេះហើយទៅអើយជឿខ្យល់មាត់ ប្រាកដជឿជាក់អស់ពីពោះ ផុងផ្ដេសគំនិតឥតពិគ្រោះ អាបោកក្អែកស្រស់យកប្រាក់បាន ៗ ទៅអើយនេះអ្នកខ្លាំងពូកែផុំម៉ែមើលឃើញគ្មានសល់ខាន ឃើញតែម្នាក់គេជឿស្លាប់ប្រាណ ទាន់អន្តរធានមកលើខ្លួន ៗ ហេតុនេះគួរទៅគិតឲ្យឆ្ងាយ ចុះបាយពាលាច្រើនបែបក្បួន បេះតាមសម័យពេញសំនួន កែខ្លួនធ្វើកល់ធ្លល់ពេញស្រុក ៗ ជួនកាធ្វើឬកបែបប្រាជ្ញប្រាយ អធិប្បាយធម៌អាថ៌ពេញបន្ទុក គ្រាក្រោយឲ្យឯងឯបពមុខ តាប់ខ្លួនឯងលក់ខូចអសារ ៗ អាណិតអ្នកនោតកោតអ្នកពាល មានច្រើនពាសកាលផ្ទលខ្សៀវខ្សារ ទៅក្រមក្រសួងតុលាការ ធ្វើទោសយ៉ាងណាក៏មិនអស់ ៗ លោកចាប់ផ្លូវនេះកាំកែនោះ ពាក្យចន់ពីពោះសំដីស្រស់ អ្នកល្ងង់បង់ទ្រព្យខូចរបស់ អាពាលយកអស់ខ្លួនខំគេ ៗ ចុះគួរអាណិតទៅល្ងង់ពេក ឆាប់ត្រេកឆាប់ជឿអ៊ូះម៉ូះទេ ទាល់ធ្លាក់បម្រើការប្រាក់គេ ខ្លួនខ្វិលគេះដរតែសព្វថ្ងៃ ៗ ព្រោះជឿអាពាលបេះទាក់ប្រាក់ ខ្វះគមកដាក់ឥតសំចៃ មិនដឹងពុតពាលខូចពេកក្រៃ យករត់ចូល

ព្រៃទៅកន្ទើយ ៗ ទម្លាប់ធ្លាប់ជឿទាំងអស់នេះ អាពុកវាចេះគ្មានសល់ ឡើយ វាធ្វើបែបនេះច្រើនដងហើយ ចៅអើយចៅឆោតអ្វីអម្បាយ ៗ មានពាលចាស់ខ្ទះឈ្លាសចង់ស្រី ទោះមានស្វាមីប្តីមេម៉ាយ ចេះលចេះ លួងប្រើលែបខាយ កិច្ចកលនាយអាយុដោយវាទៅ ៗ ដូចយ៉ាងវាធ្វើ ជាចំណាន គ្រូធម៌កម្មដ្ឋានចេះគ្រប់ផ្លូវ ស្រីៗព្រួហើយនាំគ្នាទៅ សុំរៀន ជម្រូវតាមប្រាថ្នា ៗ អាខ្លួចបានដៃនាំគេស្គាល់ រកទីប្រតិបត្តិបកធម៌អាថ៌ ឆ្ងាយក្នែកត្រចៀកមនុស្សធម្មតា បកផ្លូវយ៉ាងណាក៏បណ្តោយ ៗ មិន ព្រមតាមគ្រូឯណាបាន ផ្លូវធម៌កម្មដ្ឋានលោកគ្រូឲ្យ ទឹងគេចទឹងកែប្តីបែរ ក្រោយ ផ្តលក្លោយទៅហើយប្រឹងសំងំ ៗ ចៅប្តីដឹងជាក់ព្រួគេថា តវ៉ ជដែកស្មើរវាយជំ សរសេរអាខ្លួចថាចេះធំ មិនដឹងមានោរម្យផ្លូវខាងកន ៗ ទុកចិត្តកិរិយារៀនកម្មដ្ឋាន រៀនបានបកញយក៏ជឿស្លុង ព្រលឹមព្រលប់ ស្លុតផ្គត់ផ្គង់ ដាក់ថ្នាក់តាមអង្គុកងបន្ទប់ ៗ អ្នកប្រាប់គេឯងពីប្រពន្ធ ខំរៀនពេកពន់ទាំងថ្ងៃយប់ ខ្មោចម៉ែខ្មោចឪក៏ឃើញសព្វ គ្រូប្រាប់ថា បប់ឆាប់ជាងគេ ៗ ឱះឱអាណិតតែចៅប្តី ម្តេចជឿតែស្រីអ៊ីម៉្លេះទេ មិន ដឹងប្រពន្ធដាច់កាមេ តែព្រៃក៏ជូនគ្រូពាលណា ៗ នេះហៅប្រាក់ បង់ថង់កំដាច ពាលប្រាជ្ញអាចប្រឹងប៉ងប្រាថ្នា បែរខ្នងបែរមុខតាមត្រូវ ការ វាធ្វើយ៉ាងណាឥតសង្ស័យ ៗ មុខគួរសរសេរពាលចេះដល់ សាង ផលអតីតប្តីសម័យ ផតជាប់តាមមកជាបច្ច័យ ឥតមានទៀយអ្វីប្រាក់

ចាយសល់ ៗ បានត្រៃទេសអែកទឹងត្រៃត្រែ អ្នកស្រែបំការក៏ជួយ
ផ្តល់ ថ្លៃសាមសិបរៀលមកតាមផល បេះដល់មិនខ្វះទ្រព្យធនធាន ៗ
បើទីងសាងផលប្រសំបៃ លក់យកកំរៃធ្វើជាមាន គ្មានព្រួយលំបាកប្រអត់
ឃ្លាន កោតផលគេបានឥតមានខ្វះ ៗ ក្មេងស្តាប់ចាស់ប្រាប់តាមកិច្ចកល់
ឆ្លើយផ្តល់សួរចាស់យ៉ាងរហ័ស លោកតានេះចេះបំណាប់ណក សំ ធមិ
ចាស់ទឹកចិត្តចេះគ្មានទាល់ ៗ ឧបាយពាក្យច្រើនប្រការ គេថាប៉ុនបោក
អស់គ្មានសល់ មិនដែលជួបម្តងប្រឹងតែធ្វល់ តាធ្លាប់ធ្វើកល់បោកប្រទេ ៗ
ចាស់ព្រុក្មេងថាចំលើខ្លួន តែកូនប្រកែកថាទេៗ តាមិនដែលបោករបស់គេ
គ្រាន់តែប្រាប់ទៅឲ្យបានដឹង ៗ គេខូចប្រជួបមកលើតា កាលណា
គេព្រុគេទឹងទីង បើទៅដឹងហើយប្រាជ្ញយ៉ាងហ្នឹង ទៅរស្ងៀមឲ្យឈឹងកុំ
ចរចា ៗ ក្មេងសួរម្តងទៀតតាកំណត់ ប្រាកដមិនមែនអ្នកឯណា បោក
គេនោះពិតជាខ្លួនតា សូមតែករុណាប្រាប់ឲ្យត្រង់ ៗ ចាស់ទាល់គំនិត
គិតតែគួ ក្មេងដដែកសួរគ្មានបោះបង់ ឯងបានអធិប្បាយវិលជួបកង់ ប្រាប់
ត្រង់ថាពិតជាខ្លួនតា ៗ ទៅអើយគិតចុះជាតិយើងខ្មែរ គួរតែនឹកដល់
ព្រះសាស្តា កាលគង់ព្រះជន្មនៅឡើយណា គ្មានបានបរិក្ខារដូចេះហ្នឹង ៗ
បានជាសរសើរពីបង្ស្កូល យកស្បូវខ្មោចចោលមកទំព្រង់ បោកលាង
ឈាមខ្វះជាប់គាំងរឹង បណ្តាយទទឹងល្មមដេរជាន ៗ ធ្វើជាចីវរត្រង់
គ្រប់អង្គ អនុញ្ញាតឲ្យសង្ឃប្រើប្រាស់បាន សាវកធំៗគ្រប់ម្ចាន សិស្ស

មិនដែលបានថ្វាយត្រៃទេ ។ ព្រះសង្ឃសព្វថ្ងៃនៅក្នុងវត្ត ខ្វះអត់ស្ទើរតែ ខ្លួនទទេ ចីវររហែកស្បង់គ្មានទេ ព្រោះតែមិនចេះធម៌កម្មដ្ឋាន ។ បើចេះ មិនខ្វះរបស់អ្វី បានត្រៃព្រៃថ្មីយ៉ាងកុំផាន ប្រាក់កាសកោដនទាំងប៉ុន្មាន មិនបាច់ចង់បានក៏បានដែរ ។ ព្រះសង្ឃសម្មតិទ្រង់ព្រះផ្នួស បួសតាម ពុទ្ធដិកាសាសនាខ្មែរ ជាទក្ខិណេយ្យៈបុជាស្រែ បុណ្យខ្មែរផ្ញើទានយក កុសល ។ មិនឃើញឧបាសកថ្វាយត្រៃ គួរឲ្យសង្ស័យរឹងរឹតឆ្ងល់ លោក ជាស្រែបុណ្យបង្កើតផល ប្រឹងខ្វល់ឲ្យតែទៅគ្រហស្ថ ។ មិនដែលរក្សា ទាំងសីល៥ ឬរៀនឲ្យចាំនោះគ្មានសោះ មានលោកសង្ឃខ្លះប្រឡោះបោះ យកវត្ថុចំពោះដោយប្រពៃ ។ អ្នកបួសមិនខ្លាចខ្ចបសិក្ខា វិន្ទាមិនគិត ខុសវិន័យ គេទជាបព្វជិតទ្រង់សីលសេយ្យ ហេតុអ្វីសំពះឯគ្រហស្ថ ។ មានខ្លះដែលផ្ដាសវិទ្យាស្រី រូបមានសព្វថ្ងៃនៅស្រុកកោះ ទន្លេសង.ខាង នៅចន្ទោះ ហៅកោះស្ដេចទ្រង់ក្នុងក្របេះ ។ គ្មានគិតគ្មានយល់គិប ឡើយនៃ ប្រព្រឹត្តប្រស័យយ៉ាងដូច្នេះ ពាក្យភូតមិនពិតធាប់ជឿម៉្លេះ ស្លុងចិត្តបែបនេះគ្មានយល់អ្វី ។ ជឿថាមាតាអ្នកបុណ្យធំ បង្គំជ្រួល ជ្រើមជាប្រក្រតី ឆោតអ្វីឆោតម៉្លេះទាំងប្រុសស្រី អ្នកមានបុណ្យអ្វីកើត ប្ណេះណា ។ កាលអង្គសម្ដេចព្រះសម្ពុទ្ធ ចមមកុដតែលោកជាសាស្ដា វិសេសគោត្រត្រកូលខ្ពស់អស្ចារ្យ ក្សត្រាកបិលពស្តុបុរី ។ បានទ្រង់ ចុះចាប់យកកំណើត ត្រកូលខ្ពស់ឆើតដោយប្រពៃ មិនមែនថោកទាប

ដូចគ្រល្បី សរសើរទាសីថាមានបុណ្យ ៗ តាំងពីតាតូចតាគ្រល្បី ប្រុស
ស្រីនិយាយច្រើនពេកពន់ ខ្សឹបខ្សៀវប្រាប់គ្នាយើងចាំគន់ មើលអ្នកមាន
បុណ្យបានកើតហើយ ៗ យើងប្រុងគំនិតនឹងស្មារតី ទាំងប្រុសទាំងស្រី
កុំធ្វេសឡើយ យើងបានពានអ្នកមានបុណ្យហើយ មិនទៅឡើយម្ដាយ
នៅប្រទៅ ៗ មានទាំងឧបាសកនឹងលោកសង្ឃ ចិត្តគួចបាញ់ត្រង់សំពះ
គោ ទៅវត្តតាកែស្រុកក្បាលពោរ ថាជាព្រះគោមេគោញី ៗ ខ្លះ
ទៅសំពះសត្វឧត្ដ ពស់ទឹងអន្ទង់សត្វទាំងពីរ សុំទឹកខ្សែវល្លិ៍តាមសញ្ញី
ខ្លះបែរទៅឯមនុស្សឆ្កួត ៗ ថាអ្នកមានបុណ្យខ្លាំងពូកែ ជិតឆ្ងាយឲ្យតែ
ឮគេអួត នាំគ្នាស្រង់ក្លិនតាមអំនួត មនុស្សឆ្កួតថាជាអ្នកមានបុណ្យ ៗ
តាំងពីអន្លង់យូរឆ្នាំហើយ ចៅអើយសព្វថ្ងៃមិនគិតគន់ ជាមែនមិនមែន
អ្នកមានបុណ្យ គយគន់មិនគួរជឿពេកក្រៃ ៗ ក្មេងស្ដាប់ពាក្យចាស់
ចេះប្រាជ្ញប្រាយ លែងខាយប្រាប់គ្រប់សព្វសេចក្ដី សួរថាលោកតាចុះ
សព្វថ្ងៃ ហេតុអ្វីក៏ធ្វើបែបយ៉ាងហ្នឹង ៗ ពាក្យតាចរចាទាំងប៉ុន្មាន ខ្ញុំបាន
ស្ដាប់ចប់ខ្ញុំចង់ដឹង ចំណែកខាងតាៗកុំខឹង ចង់ដឹងឲ្យច្បាស់ពីលោក
តា ៗ លោកតាចេះធម៌ច្រើនចំឡែក ក្នុងផ្នែកខាងធម៌ព្រះសម្មា- សម្ពុទ្ធ
ជាម្ចាស់សាស្ដាចារ្យ ម្ដេចហើយលោកតាមិនប្រព្រឹត្ត ៗ ចៅអើយតា
ប្រាប់ចៅឲ្យត្រង់ បើដូចត្រឹមត្រូវបានអ៊ុលិទ្ធ តោងប្រើឧបាយតាមគំនិត
អ្នកជឿជាក់ពិតបានណាតា ៗ ទាន់គេកំពុងនៅងឿងឆ្ងល់ ច្របល់ទាស់

ទែនពល់វេលា ធម៌ចាស់ធម៌ថ្មីប្រែឈ្មោះគ្នា មុខជាស៊ុងចិត្តខ្វះមិនខាន ។ បានជាតាគិតគំនិតថ្មី គ្មានអ្វីលើសពីធម៌កម្មដ្ឋាន ប្រុសស្រីចាស់ក្មេង ទាំងពុំន្ទាន ពុទ្ធធម៌កម្មដ្ឋានចូលចិត្តណាស់ ។ ទំពាំងគេដឹងគង់យូរធ្លាយ សប្បាយសិស្សច្រើនទាំងក្មេងចាស់ លោកតាបានព្រមទាំងប្រាក់កាស ខ្លួនចាស់មិនបានទៀយកំឡាំង ។ ដល់ចាស់មែនទែនសឹមយើងគិត គំនិតធ្វើតាមព្រះអរហំ ឲ្យត្រូវតាមធម៌ជាទីតាំង សង្កេតទុកតាមយថា ។ ក្មេងឆ្លើយទៅចាស់ថាសូមទោស ពីព្រោះពេកណាស់ពាក្យលោកតា អធិប្បាយវែងឆ្ងាយជាអស្ចារ្យ កិច្ចកល់យ៉ាងណាចេះគ្មានសល់ ។ តាចេះ ចំណោះនេះយ៉ាងវៃ សព្វថ្ងៃគ្មានអ្នកណាចេះដល់ ប្រាជ្ញពិតប្រាជ្ញមែន ប្រាជ្ញកិច្ចកល់ មិនឲ្យគេឆ្ងល់ឆាប់ជឿបាន ។ ខ្ញុំខ្លាចប្រាជ្ញតាហៅចេះ ដល់ គ្មានសល់ចន្លោះតាមលំអាន ប្លែកណាស់ត្រង់ផ្លូវធម៌កម្មដ្ឋាន បញ្ចូលចិត្តបានទាំងប្រុសស្រី ។ តាថាគ្មានឃើញម៉ែឪទេ ចុះគេខំរៀន ប្រយោជន៍អ្វី តាប្រាប់ឲ្យអស់ផ្លូវសេចក្តី ពុល្យពេកណាស់ប្រាកដជាក់ ។ តាឆ្លើយសារសព្វថាចៅតា ហៅថាកម្មដ្ឋាននេះណាអ្នក បើបានរៀន ហើយត្រូវឲ្យលាក់ គ្មានជាក់ពិតទេណាចៅតា ។ ប្រាជ្ញត្រូវប្រាប់សិស្ស ថាឯងបាន កម្មដ្ឋានប្រាសហើយកុំចរចា ឲ្យអ្នកផងដឹងទឹងបែកការ កាលណានិយាយខ្សឹបឲ្យជិត ។ ចៅតាពាក្យខ្សឹបពុទ្ធឆ្ងាយណាស់ ពាក្យ ចាស់បុរាណពីអតីត ក្អែកមួយក៏ក្លាយដល់ដប់ពិត គំនិតប្រាជ្ញពាលឆ្លាត

ពេកក្រៃ ៗ ពោលពីមហាជនផងនានា ពល់គ្នាទៅតាតែសព្វថ្ងៃ ខ្ញុំនៅ នៅគល្ងង់ទាំងប្រុសស្រី គ្មានគិតសេចក្ដីបង់ឲ្យបេះ ៗ អស់លោក អ្នកប្រាជ្ញលោកប្រឹងទំ សន្សំរៀបរៀងអស់ចំណេះ ស្រាយពីបាលីឲ្យ បានបេះ ខ្ញុំពោលថាអេះធម៌បែបថ្មី ៗ ខ្ញុំមិនព្រមមើលធម៌សៀវភៅ ស្រេចនៅស៊ឹកតែយើងប្រក្រតី ខ្ញុំថាចង់ដឹងទាំងប្រុសស្រី តាមដោយ សេចក្ដីប្រហ្មត់ចត់ ៗ អ្នកខ្ញុំពោលថាធម៌បុរាណ គម្ពីរក៏មានពិតប្រាកដ ពោលនេះគឺត្រូវតាមសន្មត ប្រាកដបែបណាក៏មិនដឹង ៗ ខ្ញុំមិនដែល មើលឲ្យចងចាំ គ្រាន់តែចំណាំថាធូរតឹង ខ្ញុំពួកគ្នាថាដូចប្អឹង ប្រឹងទំ សំគាល់ថាបុរាណ ៗ អ្នកប្រាជ្ញលោកទំប្រែបាលី ឲ្យដឹងសេចក្ដីយល់ ដើមដាន ខ្មែរយើងសព្វថ្ងៃស្ដាប់មិនបាន បាលីប៉ុន្មានគ្រាន់តែចាំ ៗ ដូចជាអដ្ឋៈសូត្រតែមាត់ គេះផ្គាំកំណត់ជាចំណាំ មិនដឹងថាម្ដេចរេចខ្សែ ផ្ដាំ យូរៗយូរឆ្នាំដឹងនោះគ្មាន ៗ បដិសង្ខាយោនិសោចីវរ៌ សូត្រ ជាប្រក្រតីត្រឹមគិលាន មិនយល់ថាម្ដេចស្មានបំពាន បំរើនឲ្យបានឪពុក ម្ដាយ ៗ ខ្ញុំថាឲ្យបានទៅអ្នកស្រុក គេឲ្យបាយទឹកញាតិជិតឆ្ងាយ ខ្ញុំថាបដិសន្ធិដោះថ្លៃបាយ តាមពាក្យបរិយាយប្រាប់សេចក្ដី ៗ ក្មេង ស្ដាប់ព្រះហើយសួរទៅថា លោកតាឯងនេះពួកធម៌ថ្មី បានជាសរសើរ ប្រែបាឡី ខ្ញុំនៅសង្ស័យជាបំផុត ៗ (ដោមានគ)

# រឿងចៅឆុង-ចៅសាញ់

## បទកាកគតិ

បពិត្រអញខ្ញុំ ហត្ថាបង្គំ ប្រណម្យវន្ទា សូមមានតេជះ ដូចព្រះរាមា សូមមានប្រាជ្ញា ដូចព្រះមហោសថ ៗ ខ្ញុំថ្វាយបង្គំ ព្រះពុទ្ធឧត្តម ប្រាជ្ញាមោះមុត តែងនាំសត្វផង ឆ្លះឆ្លងសមុទ្រ សង្សារបំហុត ដាក់ដល់សួគ៌ា ៗ ព្រះអង្គត្រាស់ត្រេច សាងសំភារស្រេច ផ្តាច់វដ្តសង្សារ លើសលែងត្រៃភព សាយសព្វទិសា ព្រះអង្គផ្ចាញ់មារ ដល់និព្វានហោង ៗ បង្គំព្រះពុទ្ធ បារមីពិសុទ្ធ ពិសេសឥតហ្មង ពន្លឺរស្មី ភ្លឺក្រៃកន្លង ដល់សួគ៌នាយហោង ភ្លឺផុតសព្វស្ថាន ៗ បង្គំព្រះធម៌ ពិសេសមានអាថ៌ ជ្រៅពន់ប្រមាណ អាចតែងត្រងរង សត្វផងសព្វស្ថាន ជាខ្ទឹមប្រធាន ត្រៃពិធសម្បត្តិ ៗ បង្គំព្រះសង្ឃ ប្រសើរសឹងទ្រង់ សីលសុទ្ធប្រតិបត្តិ ជាស្រូវស្រែបុណ្យ មានគុណគាប់ក្តាត់ តាមផ្លូវប្រតិបត្តិ ព្រះសង្ឃទាំងឡាយ ៗ លោកខំសង្វាត យកបិណ្ឌបាត ប្រោសសត្វសម្មាយ ឲ្យរួចអស់ទុក្ខទោសនៅក្នុងកាយ សត្វផងទាំងឡាយ ចូរសុខាហោង ៗ

នេះនឹងស្រដី បុរសប្រុសស្រី ពីរនាក់ជាម្តង ប្តីនឹងប្រពន្ធ ឥតធនធានផង ឥតញាតិសោតហោង ឥតផៅសន្តាន ៗ រកស៊ីនៅនា ក្នុងព្រៃព្រឹក្សា យូរទៅទើបបាន កាប់ឈើរើព្រៃ នៅក្នុងស្នះសាន បន្តិចទើបបាន ចំការមួយហោង ៗ នោះឯងធំក្រៃ ប្រមាណទៅនៃ ៥ សិនជាម្តង

ជាអ្នកកំសត់ ទុគ៌តកន្ទង់ ហេតុនោះសោតហោង ត្រេកអរពេកក្រៃ ៗ លុះដាំស្រូវទៅ ក្នុងចំការក្បូរ ស្រូវនោះប្រពៃ ទឹកជាទុស្រូវ អញ្ញនេះល្អក្រៃ គុម្ពធំណាស់នៃ លើសស្រូវអ្នកផង ៗ ជាយូរលង់នៅ រីឯដើមស្រូវនោះក្បូរសោតហោង ល្អៗប្រពៃ គួរវែងកន្ទង់ ជាក់គួរល្អាយល្អង ទន់ ៗ តាមគ្នា ៗ ល្អល្អះប្រពៃ រីស្រូវនោះនៃ ទុំពេញចំការ រន្ទាលប្រាលផ្អៅ ផ្លែស្រូវនោះណា ពាសពេញចំការ បរិបូណ៌ជាត្រើយ ៗ រីឯបុរស ទាំងពីរស្មានស្មោះ បបួលគ្នាហើយ ទៅច្រូតនៃស្រូវ នោះក្បូរជាត្រើយ យកស្រូវមកហើយ ដាក់លើផ្ទះហោង ៗ លុះដល់រដូវ នាំគ្នាយកស្រូវ ទៅដាំទៀតផង ដូចកាលសព្វគ្រា ពីដើមនោះផង ស្រូវនោះឯងហោង ល្អដូចដើមនៃ ៗ យូរលង់ទៅណា បានភោជន៍អាហារ រឹតតែច្រើនក្រៃ ពេញបរិបូណ៌ណាស់ ឥតខ្វះឡើយនៃ ត្រេកអរពេកក្រៃ ធ្វើជង្រុកឯង ៗ មួយនោះធំក្រៃ ហើយវែងផងនៃ ប្រាកដជាក់ស្តែង ធេងធំទូលាយ ខ្ពស់ក្រៃគួរស្ញែង ជង្រុកប្រាំល្វែង ឥតក្រែងអ្នកផង ៗ ជាយូរទៅណា នាងមានកូនក្លា មួយល្អកន្ទង់ ឲ្យឈ្មោះកាសាញ់ ពេញចិត្តណាស់ហោង ស៊ីបាយច្រើនផង មួយឆ្នាំមួយថ្ងៃ ៗ លុះដល់គំរប់ ប្រាំមួយជណ្តប់ ឆ្នាំហើយសោតនៃ បរិភោគអាហារ កាន់តែច្រើនក្រៃ នាក្នុងមួយថ្ងៃ បីថាំងអង្ករ ៗ ម្តាយឪពុក ទេះតែកើតទុក្ខ ភ័យតែពីក្រ រីស្រូវចំការ កាន់តែមិនល្អ ភ័យតែពីក្រ

ធ្វើស្រែមិនទាន់ ៗ ទើបមកគិតគ្នា បើខំទុកដាក់ ឃើញជាមិនគ្រាន់ ពីដើមយើងមាន ឥឡូវយើងកាន់- តែថយសម្បូរ សម្បត្តិហិនក្រ ៗ រីស្រែបំការ យូរឆ្នាំហើយណា កាន់តែមិនល្អ ទុកដាក់ធ្វើអ្វី នាំតែឲ្យក្រ សម្លាប់ឲ្យមរណៈ អាចោរចង្រៃ ៗ

បទព្រហ្មគីត

ឪពុកហៅកូនហើយ អាសាញ់អើយមកឲ្យទាប់ ផ្សែងអញចង់ទៅកាប់ ឈើឯព្រៃភ្នំនោះណា ៗ អាសាញ់បានឮហើយ ដើរព្រងើយប្រាប់មាតា ថាម៉ែជាំបាយក៏ ផ្សិតខ្ញុំទៅកាប់ឈើផង ៗ ម្ដាយឮអាសាញ់ប្រាប់ ជាំបាយឆាប់ពេកកន្លង ខ្ចប់ឲ្យអាសាញ់ហោង ហើយអាសាញ់ស្ពាយដើរវៃ ៗ ឪពុកហៅអាសាញ់ កុំសូញសាញអាចង្រៃ ហើយក្រែងមិនទាន់ថ្ងៃ ទន់រៀលរវីងមិនទាន់ហោង ៗ លុះចរយាត្រាទៅ ដល់ព្រៃជ្រៅដុនដែនដង ឃើញឈើមួយធំផង សំ-ន្ធនប៉ុនបំទុបតឹង ៗ អាសាញ់ព្យួរបាយហើយ ឈរព្រងើយធ្វើមិនដឹង ឪពុកប្រឹងសំឡឹង ធ្វើទម្ងន់ទ្រមក់នៅ ៗ ឪពុកហៅថានែ អាកុំប្រែឈរសំឡឹង អញកាប់ឈើទន់ដង ចាំទទួលរុំយអាសាញ់ ៗ ឪពុកប្រឹងតែកាប់ ប្រុងសម្លាប់អាសាញ់ហ្នឹង អាសាញឈរបែរស្ទឹង ស្ទុះទៅទ្រឈើនោះណា ៗ ឪពុកស្រែកថារុំយ ប្រយ័ត្នធ្លាក់ឈើអាក៏ ឈើនេះធ្វើទុកក្ដារ កុំឲ្យបែកបាក់ឡើយរុំ ៗ ឯឈើបាក់សង្កត់

អាសាញ់ស្រុតលិចក្នុងដី ផុតពុកវែស្រែកថាថី ម្ដេចក៏លិចបាត់ទៅហើយ ៗ គិតស្រេចហើយយោត្រា ដើរម្នីម្នាមកកន្ទើយ ថាវាស្លាប់ទៅហើយ កាលណាទឹងរស់ឡើងវិញ ៗ ដើរមកធ្វើព្រះអើយ ក្លួចបាយហើយ ពុំទឹកមិញ ពុំត្រឡប់វិលវិញ ទៅយកបាយមកស៊ីឡើយ ៗ គាត់ដើរ ចិត្តទឹកគិត ក្នុងគំនិតគាត់ជាត្រើយ ពុំបានទឹកបាយឡើយ ចេះតែគិត ក្នុងត្រើយ ៗ កាលពីដើមមកនៃ អញទឹកភ័យតែពីស៊ី ឥឡូវគ្មាន គ្នាគ្នី មកតាមស៊ីបំផ្លាញឡើយ ៗ ពុំដឹងខ្លួនទឹងស្លាប់ ពៀរសម្លាប់ គេនោះហើយ គេពុំស្លាប់សោះឡើយ ពៀរនោះហើយស្លាប់ខ្លួនឯង ៗ ដើរមករកលំនៅ វង្វេងផ្លូវដាច់សង្វែង អត់បាយស្ងួតពោះធេង ប្រាំពីរ ថ្ងៃក្បៀយជន្ទា ៗ

ទឹងថ្ងៃឯហាក់ទៅវិញ ឯចៅសាញ់នៅកំព្រា ដើររួចឡើងម្នីម្នា រកបិតាពុំឃើញឡើយ ៗ ប្រឹងស្រែកដង្ហោយហៅ ថាឪឪទៅណាហើយ អញ្ជើញមកឪអើយ មកបរិភោគអាហារហោង ៗ ស្រែកហៅពុំឮឆ្លើយ ទុក្ខពុំស្បើយឧរាង ទើបវិលមកវិញផ្គង យកអាហារបរិភោគ្គា ៗ រួច ហើយទើបក្រោកដើរ ទៅយកឈើលីលើស្មា ទំហំប៉ុនបណា លីលើស្មា ហើយដើរទៅ ៗ វេរកផ្លូវទៀតណា ឯកអង្គាម្នាក់ឯងក្លូវ ឥតគ្នាជាពីរ នៅ គ្រាំទ្រដើរទៅរកមណ្ឌល ៗ រកផ្លូវដែលដើរមក ឥឡូវរកក៏ពុំយល់ ចេះតែដើរវិលវល់ ហើយអម្ពល់ក្នុងព្រៃព្រឹក្ស ៗ

បទមណ្ឌោ កាកគតិ

ចៅសាញ់ដើរទៅ រកទីលំនៅអាត្មា ពុំឃើញឡើយណា វង្វេង ក្នុងព្រៃវក់វី ៗ ទឹងថ្ងៃងតទៅ ឯម្ដាយនិត្យទៅផ្ទះខ្ទី ចាំមើលផ្លូវប្ដី ពុំឃើញ បាត់ពាល់ល្ងាចណា ៗ ចេះតែទន្ទឹង សញ្ជប់សញ្ជឹងខ្លោចផ្សា ព្រួយ ក្នុងចិន្តា ពុំបាននិទ្រាតិចឡើយ ៗ ឮមាន់រងាវ ស្មានជាប្ដីហៅគិតឆ្ងើយ បើកទ្វារឡើងហើយ រកមើលពុំឃើញឡើយណា ៗ ស្ដាប់ជាក់ជាមាន់ ក្នុងចិត្តខាញ់គ្នាន់សោះសា ជាទុអនិច្ចា អ្នកជាស្វាមីខ្ញុំនេះ ៗ ក្យ័យប្ដ ដូចម្ដេច បានជាអ្នកបាត់ដល់ម៉្លេះ ថ្ងៃមិញយប់នេះ ក៏ពុំទាន់ឃើញមុខ មាត់ ៗ មើលផ្លូវបាត់ហើយ ខាងនៅព្រៃដើយស្ងៀមស្ងាត់ ហេតុដ្បិត ប្ដីបាត់ ស្ងៀមស្ងាត់រកសុំទៅណា ៗ

នេះនឹងថាថ្លែង និទានតាមចែងចរោ ទៅចៅសាញ់ណា ឯកា ដើរតែក្នុងព្រៃ ៗ ចេះតែដើរទៅ ពុំដែលដឹងផ្លូវឡើយនៃ ដើរត្រាច់ក្នុង ព្រៃ រកផ្ទះពុំឃើញឡើយណា ៗ ឃើញប៉ុន្តែសត្វ ក្នុងចិត្តស្ងប់ស្ងាត់ សោះសា ជាទុអនិច្ចា អញអើយកំព្រាម្នាក់ឯង ៗ ខុសសត្វទាំងឡាយ នៅសុខសប្បាយឥតក្រែង អញអើយតែឯង ហោមហាចំបែងពុំស្បើយ ៗ មិនដូចសត្វផង ច្រើនក្រៃកន្ទួងជាត្រើយ មូលនឹងគ្នាហើយ ដើរទៅឯណា ច្រើនក្រៃ ៗ អញដើរតែឯង គិតគ្រប់គ្នាស្រងណាស់ខ្ញុំ ក្រែងសត្វអ្វី ៗ វាមកយាយីពាធា ៗ រីឯដើមឈើ ដែលអញលំលើស្មាណា ទើសនឹង

ព្រឹកព្រា ក៏បាក់មែកកក់ស្រឡះ ៗ ដើរមកយូរហើយ ពីរខែជាត្រើយកន្ទុះ ទំដើររកផ្ទះ ពុំឃើញពុំយល់ឡើយណា ៗ រីឯចៅសាញ់ ក្នុងចិត្តគ្នាន់ខ្នាញ់ណាស់សា ទោះតាំងអាហារ នោះក៏ពុំបានបរិភោគ ៗ ដើរតែក្នុងព្រៃ សព្រែនសព្រែងទុក្ខសោក ទំតែដើររក ពុំឃើញបេះតែយាត្រា ៗ រីដំណើរនេះ យើងទឹងទុកស្ទះក្សណណា បង្ហានទុកជាដើរតែក្នុងព្រៃឯកអង្គ ៗ

នេះនៅស្រដី ទៅឯបុរីពជរម្យ មួយនាមឧត្តម នគរព្រះបាទព្រហ្មទត្ត ៗ ព្រះអង្គសោយរាជ្យ មែនមានអំណាចពេកក្រាក់ គ្រងអស់ពស្ត្រដ្ឋ នៅក្នុងនគរភូមិស្រុក ៗ ស្ដេចសុខសប្បាយ អស់ពស្ត្រទាំង-ឡាយឥតទុក្ខ ព្រះអង្គសឹងសុខ ពុំដែលមានទុក្ខភ័យសោះ ៗ មនុស្សផងច្រើនក្រៃ សប្បាយសព្វថ្ងៃទាំងអស់ ទោះស្រីទោះប្រុស ស្រែចស្រស់ក្រេមក្សាន្តចិន្ដា ៗ ខ្លះលក់ទំនិញ អ្នកខ្លះសោតទិញគ្នាណា ខ្លះតាត់ថ្ងៃថា បីទៀនសាមសិបល្អមថ្ងៃ ៗ លក់ដូរទៅមក រអែករអាកសព្វថ្ងៃ ពុំដែលមានភ័យ ធ្លាប់សុខរៀងៗមកណា ៗ មានកាលមួយថ្ងៃយក្សមួយកាចក្រៃសោះសា ចិត្តវាមោហា វាទឹងមរណាមិនខាន ៗ យក្សនោះឯងណា ចិត្តវាហានក្លាក្នុងប្រាណ ចង់ស៊ីក្សត្រក្សាន្ត មិនដឹងខ្លួនស្លាប់ឡើយហោង ៗ ទើបយក្សមោហា ប្រាយប្រាប់ស្ដេចថាជាម្ដង ឲ្យរកមនុស្សផង មកដាក់សួយឲ្យអញថ្វាត់ ៗ បើពុំព្រមដាក់

សួយឲ្យអញដាក់ប្រាកដ ទោះទាំងមហាក្សត្រ អញសុំពុំលែងឡើយ
ណា ។ យក្សប្រាយប្រាប់ហើយ វិលវិញព្រងើយសោះសា ដល់
ស្ថានហើយណា មីម្នាចូលទៅវៃៗ ។ កាលក្រោយយក្សទៅ ព្រះ
បាទចមចៅស្តេចភ័យ ទោះពស្តមន្ត្រី ប៉ុន្មានសឹងភ័យពុំស្បើយ ។
ខ្វះវត់មីម្នា ប្រាប់គ្នីប្រាប់គ្នាថាត្រើយ ថានៃវ៉ុអើយ កុំទៅណាឆ្ងាយ
ឡើយណា ។ អស់មនុស្សទាំងឡាយ ភិតភ័យប្រញាយសោះសា
ថានុអនិច្ចា ជាហេតុប្រការកល់អ្វី ។ បេះតែកើតទុក្ខ ពុំបានចិញលក់
ឡើយនៃ បេះតែភិតភ័យ ខ្លាចក្សយជីវិតពល់គ្នា ។ ស្តេចត្រាស់ឲ្យ
ហៅ អាធុំចូលទៅមីម្នា ត្រាស់ចន្ទូលថា អាធុំអញចង់ប្រើឯង ។
ទៅថ្លែងប្រាប់យក្ស ថាអញព្រមដាក់សួយស្តែង ចាំធ្វើកខ្មែង ប្រាំពីរ
ថ្ងៃទៀតក្សណាហោង ។ ផ្សិតឯងជាអ្នក ប្រាជ្ញាជៀងជាក់ជាម្ដង
ឯងប្រាប់រាជង ដោយផ្លូវដំណើរអញថា ។ អាធុំចងចាំ ដោយផ្លូវ
បណ្ដាំពជា ទើបចង្គំលា យាត្រាវិលវិញទៅឋាន ។ ដល់មកផ្ទះហើយ
ជាទុក្ខពុំស្បើយក្នុងប្រាណ ទើបរិះគិតឃ្លាន អញយកប្រាជ្ញាបទណា ។
គិតស្រេចហើយនៃ ចុះដើរទៅវៃសោះសា រិះរកប្រាជ្ញា ដោយ
ផ្លូវឧបាយកលហោង ។ ដើរទៅហើយណា ដល់ស្ថានយក្សាដូច
បង ចរចូលទៅផ្គង ដល់នៃលំនៅយក្សស្រេច ។ ទើបយក្សសួរ
ថា ឯងមកនេះប្រការម្ដេច ដំណើរសេចក្រែច ដូចម្ដេចប្រាប់អញ

ឲ្យហើយ ៗ អាជុនឆ្លើយថា បពិត្របិតាខ្ញុំអើយ អ្នកឯងជាត្រើយ
ខ្ញុំសូមជាឪពុកខ្ញុំ ៗ ឥឡូវនេះនៃ ព្រះមហាក្សត្រថៃឧត្តម ព្រះអង្គប្រើខ្ញុំ
ឲ្យមកដាំកបោកឪ ៗ ព្រះអង្គព្រមដាក់ ស្លួយឲ្យជៀសជាក់ហើយ
ក្ប ប៉ុន្តែឲ្យឪ ចាំប្រាំពីរថ្ងៃទៀតហោង ៗ ចាំធ្វើសាលា រួចស្រេច
ហើយណាជាមួង សូមឪទៅហោង ព្រះអង្គស្ដេចដាក់ស្លួយឲ្យ ៗ
យក្សស្ដាប់ពាក្យពេចន៍ អស់អាថិសេចក្ដីគ្រប់ច្បះហើយ ឥឯងពុំស្បើយ
ហេតុៈព្រៀរកេកាត្មា ៗ ទីងក្ស័យជីវិត ខ្លួនឯងពុំគិតឡើយណា ហេតុ
ចិត្តមោហា ដែលកំបាំងស្ដេចហោង ៗ ទើបយក្សមោហា ប្រាប់
អាជុនថាជាមួង អញព្រមដែរហោង ឯងវិលទៅទូលស្ដេចចុះ ៗ
យក្សប្រាប់ស្រេចហើយ ពិតពុំលង់ឡើយកាលនោះ ទើបអាជុនផ្ដោះ
លាយក្សមកផ្ទះអាត្មា ៗ មកដល់ផ្ទះហើយ ពិតពុំលង់ឡើយម៉ិម្មា ចរចុះ
យាត្រា ទៅទូលព្រះមហាក្សត្រថៃ ៗ ទៅដល់ហើយណា ក្រាប
ទូលក្សត្រាជៀសថ្លៃជយ ឥឡូវនេះនៃ យក្សនោះព្រមហើយណា ៗ
ស្ដេចទ្រង់ជ្រាបហើយ ពិតពុំលង់ឡើយក្សត្រា ប្រាប់អស់សេនា ឲ្យ
រៀបអស់គ្រឿងប្រដាប់ ៗ ទីសួងសាលា ប្រាំពីរថ្ងៃណាឲ្យធាប់
ឲ្យបានប្រញាប់ នៅកន្លងកំណត់ប៉ុណ្ណោះ ៗ

បទពំនោល:

កាលនោះព្រះបាទក្សត្រា បង្គាប់សេនា ស្រេចហើយក៏យាង

ចូលទៅ ៗ សេនាថយចេញទៅក្រៅ ទើបបង្គាប់ទៅ អស់ទាំងភ្នាក់ងារទាំងឡាយ ៗ ឲ្យនាំឈើចូលមកអាយ ផ្សិតព្រះធោមធាយ ព្រះអង្គឲ្យធ្វើសាលា ៗ ភ្នាក់ងារស្តាប់ព្រះអាជ្ញា ហៅគ្នាម្នីម្នា នាំឈើចូលមកដាប់វៃ ទើបរៀបប្រដាប់ទីទៃ នាំឈើពីព្រៃ រំពេចដូចព្រះបង្គាប់ ៗ ខ្លះគៀនគ្នាថាប្រញាប់ រៀបធ្វើឲ្យឆាប់ ឲ្យរួចដូចព្រះអាជ្ញា ៗ ខ្លះធ្វើប្រញាប់ម្នីម្នា លុះរួចសាលា ទើបចូលទៅក្រាបទូលហោង ៗ ព្រះបាទព្រហ្មទត្តប្រាសប្បូង ទ្រង់ជ្រាបហើយហោង ឲ្យហៅអាឃុងចូលទៅ ៗ អាមាត្យរតដល់លំនៅ អាឃុងហើយហៅ ប្រាប់ទៅដូចព្រះឧង្ការ ៗ ទ្រង់មានព្រះបន្ទូលថា ឲ្យទៅម្នីម្នា ឥឡូវដូចព្រះប្រញាប់ ៗ អាឃុងនោះបានស្តែងស្តាប់ បន្ទូលឲ្យប្រាប់ ប្រញាប់រៀបអង្គអាត្មា ៗ ចរចុះដើរទៅម្នីម្នា ដល់ចុងពេនណា ក្រាបថ្វាយបង្គំក្សត្រថ្ងៃ ៗ ព្រះអង្គទតយល់អាក្រៃ បន្ទូលថាហៃ អាឯងរកមនុស្សដាក់ស្នួយ ៗ មនុស្សដែលមានទោសដល់មួយ មរណ៍ឯងកុំព្រួយ ដាក់ស្នួយនាថ្ងៃមួយហោង ៗ អាឃុងក្រាបលាជាម្តង យកមនុស្សទោសផង ទៅដាក់ស្នួយដូចបង្គាប់ ៗ រួចហើយថយចេញប្រញាប់ វិលវិញក្រឡាប់ ដើរមកផ្ទះទាំងភ័យភ្ញាក់ ៗ

នឹងថ្លែងតតែងរៀងជាក់ ទៀងទៅឯយក្ស អបលក្ខណ៍ចោរកាចចង្រៃ ៗ ដល់គ្រប់គំរប់នាថ្ងៃ យក្សចោរចង្រៃ មោហាការកាចអប្រិយ ៗ

មកដល់សាលាហើយខ្លី ចូលចាប់ម្នាម្នី ហែកស៊ីសាច់មនុស្សនោះទៅ ៗ
តែសព្វៗថ្ងៃនិត្យនៅ ៖ លុះបានដល់ទៅ ប្រាំថ្ងៃនោះឯងហោងណា ៗ

យើងស្មេះពុំទាន់ចរចា នេះនឹងថ្លែងថា ទៅឯចៅសាញ់ជាត្រើយ ៗ
មកដល់ក្នុងចុងស្រុកហើយ ព្រួយប្រាណពុំស្បើយ ចរខែប្រាកដជា
មួង ៗ អត់បាយដើរតែឯងផង ចរែះហើយហោង ដើរតែក្នុងព្រៃជាក់
ស្តែង ៗ គន់គិតក្នុងចិត្តអង្គឯង អ្នកឯណាតែង សាលាដាក់ទានទៅ
នេះ ៗ ហើយនឹកថាក៏ពុំអញអេះ បានសាលានេះ ត្រាន់ឈប់អាស្រ័យ
ជាមួង ៗ លុះដើរដល់សាលាហោង ចំលាក់ឈើផ្គង ក៏ឮសន្ធឹកខ្លាំង
ក្រៃ ៗ ទឹងថ្លែងទៅអាក្នុងនៃ ពុំស័ព្ទខ្លាំងក្រៃ នឹកថាសន្ធឹកស័ព្ទអ៊ី ៗ
គិតស្រេចទើបចុះទៅដី ដើរទៅចាប់ខ្ចី ក៏ឃើញអាសាញ់ក្រអេះ ៗ
ហើយនឹកថាអាដែងនេះ មកពីណាអេះ គួរអញនឹងទៅសួរពេ ៗ គិត
ស្រេចហើយចរយាត្រា ទៅដល់សាលា ក៏ឃើញនៃឈើនោះហោង ៗ
ឃើញធំពន់ពេកកន្ទួង គួរខ្លាចជាមួង គួរយកគេជាក្មេអញ ៗ គិត
ស្រេចទើងទៅឃាត់ខាញ់ ហៅថាសំឡាញ់ ឯងមកពីស្ថានឯណា ៗ
អាសាញ់ឮហើយឆ្លើយថា ដោយព្រៃកិច្ចា គាត់ក៏ឃ្លានបាយផង ៗ
រីឯខ្លួនអញនេះហោង ពុំដឹងស្រុកផង ដើរតែក្នុងព្រៃទណា ៗ ចរែខ
លំបាកអាត្មា ទោះទាំងអាហារ នោះក៏ពុំបានបរិភោគ ៗ ពុំដឹងទីស្ថាន
ផ្លូវច្រក ចេះតែដើរមក ទើបបានឃើញសាលានៃ ៗ ទើបណាស់ចូល

ឈប់អាស្រ័យ សាលានេះនៃ សំពកកំឡាំងក្យណាហោង ។ ចាំតែបាត់
ក្តៅពេយខ្លួន នឹងយាត្រាផ្គង ទៅគេលំនៅជាត្រើយ រីឯអាធុងចុះឆ្លើយ
ថាសំឡាញ់អើយ ចូរឯងទៅនៅនឹងអញ ។ ទោះទាំងបាយទឹកនោះ
មិញ ឆានានៅអញ ទឹងចិញ្ចឹមឯងជាមួង ។ អាសាញ់ផ្ទាស់ឆ្លើយ
រឹងស្លង ថាអញនេះហោង បរិភោគអាហារច្រើនក្រៃ ។ អាធុងថា
អញសង្ស័យ ឯងស៊ីច្រើនក្រៃ មួយថ្ងៃគេអស់ប៉ុន្មាន ។ អាសាញ់ឆ្លុះ
ឆ្លើយរឹងថ្កាន អញស៊ីប្រមាណ តិចទេមួយថ្ងៃបីថាំង ។ អង្ករសស្រែត
សម្រាំង មួយថ្ងៃបីថាំង នោះឯងទើបបានគ្រាន់អញ ។ អាធុងឆ្លើយ
ថាសំឡាញ់ ឆានានៅអញ ចិញ្ចឹមរក្សាឯងហោង ។ អាសាញ់ព្រម
ពាក្យជាមួង ទើបចុះទៅផ្គង ជាមួយនឹងអាធុងណា ។ លើកឈើលីទៅ
សោះសា ហើយបរយាត្រា មមាទៅផ្ទះអាធុង ។ ដល់ហើយទំលាក់ពុក្គង
មុខផ្ទះអាធុង ក៏បែកខ្ចាត់ខ្ចាយពីគ្នា ។ អាធុងប្រាប់ទៅភរិយា នូវអស់
មនុស្សម្នា ឲ្យរកបាយបីខ្ទះគ្នោត ។ អស់ខ្ទុំដណ្តាំបាយសោត បានបី
ខ្ទះគ្នោត ស្រេចឲ្យអាសាញ់បរិភោគ ។ សម្លស្ងោបន្ទុំឃ្លោក អាសាញ់
បរិភោគ បីខ្ទះក៏អស់ទៅហោង ។ រីអស់មនុស្សម្នាទោះផង សឹងស្ញើង
កន្ទង់ ព្រោះយល់បរិភោគច្រើនក្រៃ ។ ព្រឹកល្ងាចលុះបានពីរថ្ងៃ កំឡាំង
ច្រើនក្រៃ ដូចកាលពីដើមនៅដែលជាក់ ។

ទិនថ្ងៃនថែងទៅឯយក្ស កំណត់ជាក់ ជាក់យក្សក្នុងថ្ងៃនោះនៃ ៗ រសៀលព្រះសុរិយោទ័យ អាសាញ់នៃ បរិភោគបាយរួចហើយហោង ៗ ទើបអាធុងប្រាប់ដើមទង អាសាញ់ជាម្ចាស់ អញប្រើឯងទៅទារប្រាក់ ៗ ផ្សិតនុអញ គាត់ជំពាក់ ឯងទៅទារប្រាក់ យកមកគ្រាន់ទិញស្រូវស៊ី ៗ បន្តិចគាត់មកឯទី សាលានោះទ្វី ឯងទៅចាំគាត់មុខណា ៗ អាសាញ់ បានស្តាប់បញ្ជូ ទើបចរយាត្រា ទៅឯសាលានោះនៃ ៗ លុះថ្ងៃ ប៉ាំងទិងមាត់ព្រៃ យក្សហោះចរព្រៃ ហោះមករកចាប់មនុស្សផ៊ី ៗ យក្ស ដល់សាលាមន្ទីរ ឡើងទៅចាប់ទ្វី ដល់នៃមាត់ទ្វារជាត្រើយ ៗ អា-សាញ់ក្រឡេកឃើញហើយ ថានៃនុអើយ អាធុងឲ្យទារប្រាក់ ៗ យក្សស្តាប់ពាក្យអាសាញ់ជាក់ ស្រដីទារប្រាក់ យក្សក្រោកកាន់កាំងស្នា-ទី ៗ យក្សថាជំពាក់ប្រាក់អ្វី អញពុំមានក្តី ជំពាក់ប្រាក់កាសឱណា ៗ អាសាញ់ឆ្លុះឆ្លើយទៅថា អាធុងចរចា ថានុជំពាក់ជាម្ចាស់ ៗ មួយកន្តាំង ប៉ុណ្ណោះហោង ហេតុនោះជាម្ចាស់ ទើបពប្រើខ្ញុំមកទារ ៗ យក្សស្តាប់ពុំ ចេញចរចា ស្ទុះទៅប្រាំ ចាប់ទូរអាសាញ់ខ្ជាប់ហើយ ៗ ប្រាប់កមិន លេងឡើយ ទើបអាសាញ់ឆ្លើយ ថានុលេងអញចេញក៏ ៗ លេងអ្វីដៃធ្ងន់ ពេកណា លែងអញចេញក៏ លេងម្តេចដៃធ្ងន់អម្បាយ ៗ ឲ្យលែងមិន លែងគេឆាយ ប្រាប់ស៊ើរថ្លាយ បំពង់កគេជាម្ចាស់ ៗ អាសាញ់ប្រាប់ទៅ

ច្រើនដង មិនលែងឡើយហោង ថានៃគុលែងអញចេញ ៗ បន្តិចត្រូវកំភ្លៀងមិញ មិនលែងកចេញ អញទះកំភ្លៀងឥឡូវ ៗ កុំលេងដៃធ្ងន់ពេកក្រូវ ទើបថានៃគុ លែងអញឲ្យឆាប់ម៉ឺម៉ា ៗ យក្សស្លាប់ពុំលែងឡើយណា ខំតែប្រវា កាប់កឲ្យបាក់ជាម្ដង ៗ អាសាញ់គ្រោធក្រៃកន្លងអត់ពុំបានហោង ក៏ទះកំភ្លៀងនៃយក្ស ៗ នោះស្លាប់ទៅប្រាកដជាក់ អាសាញ់លោតឆាក់ ថែមត្រូវមួយចុងជើងទៀត ៗ ទើបអាសាញ់វាទៅធ្មៀត ស្ដាប់ដង្ហើមទៀត ក៏ផុតដង្ហើមជាត្រើយ ៗ ខ្លួនក៏ត្រជាក់អស់ហើយ ទើបគិតជាត្រើយ អានេះវាស្លាប់ហើយណា ៗ

(នៅមានត)

## ការតាំងចៅអធិការនិងមន្ត្រីសង្ឃ

ដែលទើបតាំងថ្មីក្នុងខែហ្វេវ្រីយេ ១៩៤៣

១- សញ្ញាប័ត្រលេខ ៧ ចុះថ្ងៃ ៩-២-៤៣ តាំងគ្រូសូត្រសោក-ឌិម កើតឆ្នាំច អាយុ ៥៣ វស្សា ៣៧ នាមឆាយា ចន្ទត្ថេរ ជាចៅអធិការវត្តពោធិព្រឹក្ស ឃុំកញ្ជរ ស្រុកឆ្លូង ។

២- សញ្ញាប័ត្រលេខ ៨ ចុះថ្ងៃ ៩-២-៤៣ តាំងគ្រូសូត្រវិក-មុត កើតឆ្នាំជូត អាយុ ៤៦ វស្សា ១៩ នាមឆាយា ធម្មជោត ជាចៅអធិការវត្តក្រហមក ឃុំតាម៉ៅ ស្រុកឆ្លូង ។

៣- សញ្ញាប័ត្រលេខ ៩ ចុះថ្ងៃ ៩-២-៤៣ តាំងគ្រូសូត្រអ៊ឹម-ខិម កើតឆ្នាំមមែ អាយុ ៧៦ វស្សា ៥២ នាមឆាយា កិត្តិបញ្ញា ជាចៅអធិការ វត្តពោធិព្រឹក្ស ឃុំលាំងកែន (ស្រុកកណ្ដាលស្ទឹង) ។

៤- សញ្ញាប័ត្រលេខ ១០ ចុះថ្ងៃ ១០-២-៤៣ តាំងគ្រូសូត្រនាង-មុត កើតឆ្នាំរកា អាយុ ៣៤ វស្សា ១១ នាមឆាយា វិនយរក្ខិតោ ជាចៅអធិការវត្តពោធិធំ ឃុំចំបក់ ស្រុករំដួល ។

៥- សញ្ញាប័ត្រលេខ ១១ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រឡុង-ម៉ុប កើតឆ្នាំមមី អាយុ ៣៧ វស្សា ១៧ នាមឆាយា មុនិត្ថេរ ជាចៅអធិការវត្តពោធិអម្ពិល ឃុំសំបួរ (ទ្រាំង) ។

៦- សញ្ញាប័ត្រលេខ ១២ ចុះថ្ងៃ ២៦-២-៤៣ តាំងគ្រូសូត្រ ទេស-សេន កើតឆ្នាំខាល អាយុ ៤១ វស្សា ២០ នាមឆាយា ព្រហ្ម-សុវណ្ណ ជាចៅអធិការវត្តប្រាម្បីមុម ឃុំប្រាម្បីមុម ស្រុកទ្រាំង ។

៧- សញ្ញាប័ត្រលេខ ១៣ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ ហ៊ីង-សុិន កើតឆ្នាំរោង អាយុ ៣៩ វស្សា ១៩ នាមឆាយាសុវណ្ណបញ្ញា ជាចៅអធិការវត្តព្រៃឈើទាល់ ឃុំធ្លក ស្រុកទ្រាំង ។

៨- សញ្ញាប័ត្រលេខ ១៤ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ ឯម-ង៉ែត កើតឆ្នាំរកា អាយុ ៣៤ វស្សា ១៣ នាមឆាយា លិខិតត្ថេរ ជាចៅអធិការវត្តបាពយណ៍វិហារតីរ ឃុំព្រៃស្លឹក (ទ្រាំង) ។

៩- សញ្ញាប័ត្រលេខ ១៥ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ កោះ-និន កើតឆ្នាំជូត អាយុ ៣១ វស្សា ១១ នាមឆាយា ចន្ទបញ្ញា ជាចៅអធិការវត្តសួរគីសួស្តិ៍ ឃុំធ្លក ស្រុកធ្លក (ទ្រាំង) ។

១០- សញ្ញាប័ត្រ លេខ ១៦ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ សៅ-តាក កើតឆ្នាំថោះ អាយុ ៤០ វស្សា ២០ នាមឆាយា ធម្មសុវណ្ណ ជាចៅអធិការ វត្តស្វាយជួរ ឃុំប្រាំបីមុម ស្រុកទ្រាំង ។

១១- សញ្ញាប័ត្រលេខ ១៧ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ ហេង-កុល កើតឆ្នាំមមី អាយុ ៣៧ វស្សា ១៧ នាមឆាយា កន្តត្ថេរ ជាចៅអធិការវត្តគោកខ្ពស់ ឃុំសំបួរ ស្រុកទ្រាំង ។

១២-សញ្ញាប័ត្រលេខ ១៨ ចុះថ្ងៃ ២៥-២-៤៣ តាំងគ្រូសូត្រ អ៊ឹម-ប៊ូ កើតឆ្នាំម្សាញ់ អាយុ ៣៨ វស្សា ១៥ នាមឆាយា ព្រហ្មត្ថេរ ជាចៅអធិការវត្តពោធិសួគ៌ ឃុំផ្កាយពណ៌ ស្រុកត្រាំង ។

១៣-សញ្ញាប័ត្រលេខ ១៩ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ ច័ន-យុត កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ៨ នាមឆាយា ខន្ធត្ថេរ ជាចៅអធិការ វត្តពោធិទន្ទឹម ឃុំសំបួរ ស្រុកត្រាំង ។

១៤-សញ្ញាប័ត្រលេខ ២០ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ យូរ-គ្រិប កើតឆ្នាំកុរ អាយុ ៣២ វស្សា ១២ នាមឆាយា បឋមត្ថេរ ជាចៅអធិការវត្តបន្ទាយ ឃុំត្រពាំងធំ (ត្រាំកក់) ។

១៥-សញ្ញាប័ត្រលេខ ២១ ចុះថ្ងៃ ២៤-២-៤៣ តាំងគ្រូសូត្រ ទៀវ-ធា កើតឆ្នាំកុរ អាយុ ៤៤ វស្សា ២៣ នាមឆាយា ឥន្ទកេសរ ជាចៅអធិការវត្តវិហារទោស ឃុំទ្រពាំងធំ (ត្រាំកក់) ។

១៦-សញ្ញាប័ត្រលេខ ២២ ចុះថ្ងៃ ២៤-២-៤៣ តាំងគ្រូសូត្រ ម៉ុ-គាំ កើតឆ្នាំមមី អាយុ ៣៧ វស្សា ៧ នាមឆាយា ធម្មបញ្ញា ជាចៅអធិការវត្តសាគ្រាម ឃុំសាគ្រាម (កំពង់ស្វាយ) ។

១៧-សញ្ញាប័ត្រលេខ ២៣ ចុះថ្ងៃ ២៤-២-៤៣ តាំងគ្រូសូត្រ ម៉ែន-ជួរ កើតឆ្នាំកុរ អាយុ ៥៦ វស្សា ៣៦ នាមឆាយា ធនត្ថេរបញ្ញាគិរី ជាចៅអធិការវត្តប្រែសមាស ឃុំត្រប់ ស្រុកដើមព្រៃ ។

១៨- សញ្ញាប័ត្រលេខ ២៤ ចុះថ្ងៃ ២២-២-៤៣ តាំងគ្រូសូត្រ សៅ-ទូច កើតឆ្នាំកុរ អាយុ ៣២ វស្សា ១២ នាមឆាយា ឥន្ទសុវណ្ណ ជាចៅអធិការវត្តកោះជុំ ឃុំដងទ្បង ស្រុកបាកាន ។

### ដំណឹងសុំអនុញ្ញាតធ្វើបុណ្យ

បញ្ចុះខណ្ឌសីមាក្នុងខែហ្វេប្រ៊ុយេ ១៩៤៣

១- ចុតហ្មាយលេខ ៥៥ C ចុះថ្ងៃ ៨-២-៤៣ អ្នកអាចារ្យ ដោក-ឈុន, សុំអនុញ្ញាតធ្វើបុណ្យបញ្ចុះសីមា វត្តអម្ពិលទ្វារ, ឃុំសំពង់ដៃ ស្រុកជើងព្រៃ ខែត្រកំពង់ចាម ចំនួន ៤ ថ្ងៃ គិតពីថ្ងៃ ១៨ ដល់ ២១ ម៉ារ្ស ១៩៤៣ នេះ ។

២- ចុតហ្មាយលេខ ៥៦ C ចុះថ្ងៃ ៨-២-៤៣ អំពីអាចារ្យ សេក-ឌី សម្រាប់វត្តប្រែគល់ ឃុំព្រែកពោធិ៍សួស្តី ស្រុកស្រីសន្ធរ ខែត្រកំពង់ចាម សុំអនុញ្ញាតធ្វើបុណ្យបញ្ចុះសីមា ៤ ថ្ងៃ គិតពីថ្ងៃ ៣០ ម៉ារ្ស ដល់ថ្ងៃ ២ អាវ្រីល ១៩៤៣ ។

៣- ចុតហ្មាយលេខ ៦៤ C ចុះថ្ងៃ ១១-២-៤៣ អំពីអាចារ្យ ម៉ម-អ៊ុម, សម្រាប់វត្តដីមាន់ ឃុំក្រែក ស្រុកត្បូងឃ្មុំ សុំអនុញ្ញាតធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៣ ថ្ងៃ គិតពីថ្ងៃ ១៥ ដល់ថ្ងៃ ១៧ ម៉ារ្ស ១៩៤៣ នេះ ។

៤-ចុតហ្មាយលេខ ១០២ ចុះថ្ងៃ ២៦-២-៤៣ អំពីអាចារ្យ ប្រាក់-ឡុង, សម្រាប់វត្តព្រៃសុវណ្ណ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង សុំធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៣ ថ្ងៃ គិតពីថ្ងៃ ១៧ ដល់ថ្ងៃ ១៩ អាវ្រិល ១៩៤៣ នេះ ។

៥-ចុតហ្មាយលេខ ១០៣ ចុះថ្ងៃ ២៦-២-៤៣ អំពីអាចារ្យ សុក-អ៊ីន, សម្រាប់វត្តអម្ពិល ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង សុំធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ចំនួន ៣ ថ្ងៃ គិតពីថ្ងៃ ១០ ដល់ថ្ងៃ ១២ មេ ១៩៤៣ នេះ ។

# ប្រស្នាធម៌

## អំពីព្រះនិព្វាន?

បុច្ឆា: គេថាព្រះអរហន្តស្លាប់ទៅសូន្យមែនឬ?

វិសជ្ជនា: តាមធម្មតា យើងគេកល់គាដែលនៅជាបុថុជ្ជន មិនអាចយល់ច្បាស់ពាក្យនេះក៏ប្រែសារនេះបាននេះ ប៉ុន្តែបើគេទៅតាមស្ដាប់ អានយោបល់ព្រះអរហន្តហាក់ដូចជាព្រះអរហន្តផល់មរណភាពទៅមិនមែនជាសូន្យឈឹងទេ ទើបលោកពោលថា ព្រះអរហន្តចូលនិព្វាន ឯព្រះនិព្វាននោះ ជាស្ថានរំលត់ទុក្ខ ប្រកបដោយសេចក្ដីសុខតែម្យ៉ាង ដូចព្រះពុទ្ធភាសិតថា "និព្វានំ បរមំ សុខំ" ព្រះនិព្វានជាធម៌ជាតប្រកបដោយសេចក្ដីសុខយ៉ាងក្រៃលែង ។ មួយវិញទៀត ព្រះអរហន្តតែងយល់ថា ខន្ធជាគុទុក្ខ ជាទីប្រជុំកើតឡើងនៃទុក្ខ មានជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ និងមរណទុក្ខជាដើម ទើបលោកដកចិត្តចេញចាកខន្ធ ៥ ឥតឧបាទាន ពិចារណាខន្ធទាំង ៥ ឲ្យឃើញពិតតាមព្រះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ខន្ធ៥កើតឡើងហើយតែងរលត់ទៅវិញជាធម្មតា ដូចមានសេចក្ដីសារកច្ឆារបស់ព្រះមហាសារីបុត្តត្ថេរនិងយមកភិក្ខុ សំដែងទុកក្នុងសុត្តន្តបិដក ភាគទី ៣៣ ត្រង់ខន្ធសំយុត្ត មជ្ឈិមបណ្ណាសក: ថេរវគ្គទី ៤ បទ: ទី ១៩៨ មានសេចក្ដីសង្ខេបថា:

ក្នុងសម័យមួយនោះ មានភិក្ខុមួយរូបឈ្មោះយមកៈ កើតមានទិដ្ឋិអាក្រក់ យល់ខុសថា "អញដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដូចជាព្រះខីណាស្រពតែទំលាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់ខាតសូន្យវិនាសបាត់ទៅមិនកើតទៀតទេ" ។ ឯភិក្ខុទាំងឡាយជាច្រើនបានដឹងបានឮពាក្យនេះហើយ ក៏ចូលទៅរកយមកភិក្ខុហើយសួរថា លោកយល់ថាព្រះខីណាស្រពតែទំលាយខន្ធហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅរមែងដាច់ខាតសូន្យទៅមិនកើតទៀត មែនដូច្នេះទេ ? យមកភិក្ខុក៏ទូលថា ខ្ញុំករុណាយល់ហើយ ពោលដូច្នេះមែន ។ ពួកភិក្ខុទាំងនោះក៏យល់ទាស់ថា ម្នាលអាវុសោយមកៈ លោកកុំពោលយ៉ាងនេះឡើយ លោកកុំពោលបង្កាច់ព្រះដ៏មានព្រះភាគ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះព្រះអង្គមិនបានត្រាស់ថា ភិក្ខុជាខីណាស្រពតែទំលាយកាយហើយខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់ខាតសូន្យ មិនកើតទៀតយ៉ាងនេះទេ ។ ឯយមកភិក្ខុក៏មិនយល់ព្រមតាមភិក្ខុទាំងនោះឡើយ នៅតែប្រកាន់តាមយោបល់យល់ឃើញរបស់ខ្លួនដដែល ពួកភិក្ខុទាំងនោះក៏មិនអាចដោះស្រាយដូចម្ដេចតទៅទៀតបាន ទើបនាំគ្នាទៅនិមន្តព្រះសារីបុត្តត្ថេរ ឲ្យលោកជួយនិយាយពន្យល់ ដោះស្រាយសេចក្ដីយល់ខុសរបស់យមកភិក្ខុផង ។ ទើបព្រះ

សារីបុត្តត្ថេរបោទសួរព្រះយមកត្ថេរថា ម្នាលអាវុសោយមកៈ លោកមានសេចក្ដីយល់ឃើញ មានសភាពដូច្នេះពិតមែនឬ? ។

យមកៈ ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ ។

សារីបុត្ត ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច រូបទៀងឬមិនទៀងទេ ។

យ. មិនទៀងទេ អាវុសោ ។

សា. ចុះវេទនា សញ្ញា សង្ខារ វិញ្ញាណ តើទៀងឬមិនទៀងទេ ។

យ. មិនទៀងទេ អាវុសោ ។

សា. ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្ដីនោះដូចម្ដេច លោកពិចារណាឃើញរូប វេទនា សញ្ញា សង្ខារៈវិញ្ញាណ ថាជាសត្វឬ ។

យ. មិនមែនដូច្នោះទេ អាវុសោ ។

សា. ចុះលោកសំគាល់ពិចារណាឃើញថា សត្វមានក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឬ ។

យ. មិនមែនដូច្នោះទេ អាវុសោ ។

សា. ចុះលោកពិចារណាឃើញថា សត្វផ្សេងពីរូប វេទនា សញ្ញា សង្ខារ វិញ្ញាណទៅឬ ។

យ. មិនមែនដូច្នេះទេ ។

សា. ចុះលោកពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណថាជាសត្វឬ ។

យ. មិនមែនដូច្នោះទេ ។

សា. ចុះលោកពិចារណាឃើញសត្វនេះថា មិនមានរូប មិនមានវេទនា មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណឬ ។

យ. មិនមែនដូច្នោះទេ ។

សា. ម្នាលអាវុសោយមកៈ កាលបើលោកកំណត់សត្វថាទៀងថាពិត ក្នុងបច្ចុប្បន្ននេះហើយ ទើបគួរលោកពោលថា អញដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដូចជាព្រះខីណាស្រព តែងំលាយកាយហើយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ រមែងដាច់ខាតសូន្យទៅ មិនកើតទៀតទេដូច្នេះបាន ។

យ. ម្នាលអាវុសោសារីបុត្ត កាលពីដើមខ្ញុំមិនដឹងថា ទិដ្ឋិរបស់ខ្ញុំនោះជាទិដ្ឋិខុសអាក្រក់ទេ ឥឡូវនេះខ្ញុំលះបង់ទិដ្ឋិអាក្រក់នោះហើយ ព្រោះបានស្ដាប់ព្រះធម្មទេសនារបស់ព្រះសារីបុត្តដ៏មានអាយុនេះ មួយវិញទៀត ខ្ញុំក៏បានសម្រេចធម៌វិសេសផងហើយ ។

សា. ម្នាលអាវុសោយមកៈ បើជនទាំងឡាយគេសួរលោកយ៉ាងនេះថា ម្នាលអាវុសោភិក្ខុឯណា ជាព្រះអរហន្តខីណាស្រព ភិក្ខុ

នោះទំលាយកាយហើយ ខានមុខអំពីសេចក្ដីស្លាប់ទៅនឹងកើតទៀតឬ ដូច្នេះ តើលោកគប្បីព្យាករដូចម្ដេចទៅ ។

យ. ម្នាលអាវុសោ បើមានគេសួរខ្ញុំយ៉ាងនេះ ខ្ញុំគប្បីព្យាករថា ម្នាលអាវុសោ រូបមិនទៀងទេ រូបឯណាមិនទៀង រូបនោះជាទុក្ខ រូបឯណាជាទុក្ខ រូបនោះរលត់ទៅ ដល់នូវសេចក្ដីវិនាសទៅ ឯវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលមិនទៀងជាទុក្ខក៏រលត់ទៅ ដល់នូវសេចក្ដីវិនាសទៅដែរ ។

សា. ម្នាលអាវុសោយមកៈ ត្រូវហើយៗ ខ្ញុំនឹងធ្វើសេចក្ដីឧបមាឲ្យលោកស្ដាប់ ដើម្បីឲ្យសេចក្ដីនោះច្បាស់លាស់ឡើងទៀត ។

ម្នាលអាវុសោយមកៈ ដូចជាគហបតីឬបុត្ររបស់គហបតីជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ តែងដោយការរក្សាខ្លួនយ៉ាងមាំមួន តោះបីបុរសណាមួយមានប្រាថ្នាចង់សម្លាប់គហបតីឬគហបតីបុត្រនោះ ក៏គិតត្រិះរិះយ៉ាងនេះថា គហបតីឬគហបតីបុត្រនេះ ជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ មានការរក្សាខ្លួនមាំមួន អញមិនងាយនឹងទៅសម្លាប់គេបានទេ ដូច្នេះ មានតែអញចូលទៅនៅបំរើ ធ្វើឧបាយល្បងលួងលោមឲ្យបានស្និទ្ធទុកចិត្តគាស់និសម្លាប់ បុរសនោះចូលទៅសូមនៅបំរើគហបតីឬគហបតី-បុត្រនោះ ប្រព្រឹត្តជាទីគាប់ចិត្ត ពោលតែពាក្យជាទីស្រឡាញ់ពេញចិត្ត ឯគហបតីឬគហបតីបុត្រ ក៏ជឿទុកចិត្តថា បុរសនោះជាមិត្តស្រផង

ជាអ្នកមានចិត្តល្អផង ក៏មានសេចក្តីស្និទ្ធស្នាលនឹងបុរសនោះ លុះវេលាក្រោយមកគហបតីឬគហបតីបុត្រ កំពុងនៅក្នុងទីស្ងាត់ បុរសនោះក៏សម្លាប់គហបតីឬគហបតីបុត្រនោះ ដោយសស្ត្រាដ៏មុត ។

ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនេះដូចម្តេច កាលដែលបុរសចូលទៅសូមនៅបម្រើគហបតីឬគហបតីបុត្រក្តី វេលាធ្វើការជាទីពេញចិត្តក្តី វេលានៅក្នុងទីស្ងាត់ក្តី ក៏គហបតីឬគហបតីបុត្រនោះមិនដឹងថាបុរសនេះជាអ្នកសម្លាប់ខ្លួនដូច្នេះមែនទេ ។

យ. ត្រូវហើយអាវុសោ ។

សា. ម្នាលអាវុសោ បុថុជ្ជនអ្នកមិនចេះដឹង មិនធ្លាប់ឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនធ្លាប់ឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ រមែងមើលឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួនខ្លះ ឃើញខ្លួនថាមានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះ ឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណក្នុងខ្លួនខ្លះ ឃើញខ្លួនក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះ ។ បុថុជ្ជននោះរមែងមិនដឹងច្បាស់តាមសេចក្តីពិតថា រូប វេទនា សញ្ញា សង្ខារ-វិញ្ញាណ មិនទៀងជាទុក្ខមិនមែនជាខ្លួនមានបច្ច័យតាក់តែងឡើង រមែងមិនដឹងច្បាស់នូវរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអ្នកសម្លាប់ឡើយ ។ បុថុជ្ជននោះរមែងចូលទៅប្រកាន់ខ្ជាប់ នូវរូប វេទនា សញ្ញា

សង្ខារ វិញ្ញាណ ថាជារបស់អញ ឧបាទានក្ខន្ធទាំង៥នេះ ដែលបុថុជ្ជន ចូលទៅប្រកាន់ខ្ជាប់ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីជាទុក្ខ អស់កាលជាអង្វែង ។

ម្នាលអាវុសោយមកៈ ឯព្រះអរិយសាវកជាអ្នកចេះដឹង ធ្លាប់បានឃើញពួកព្រះអរិយៈ ឈ្លាសវៃក្នុងអរិយធម៌ ធ្លាប់បានឃើញពួកសប្បុរស ឈ្លាសវៃក្នុងសប្បុរិសធម៌ រមែងមិនឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន មិនឃើញខ្លួនថា មានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណក្នុងខ្លួនក្តី មិនឃើញខ្លួនក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណក្តី ។ អរិយសាវកនោះ រមែងដឹងច្បាស់តាមពិតថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀងជាទុក្ខមានបច្ច័យតាក់តែងឡើង ។ ដឹងច្បាស់តាមពិតថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ហ្នឹងឯងជាអ្នកសម្លាប់ ។ អរិយសាវកនោះមិនចូលទៅជិត មិនប្រកាន់ខ្ជាប់ មិនតាំងស៊ប់នូវរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួនរបស់អញ ។ ឧបាទានក្ខន្ធទាំង៥នេះ ដែលព្រះអរិយសាវក មិនចូលទៅជិត មិនប្រកាន់ខ្ជាប់ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ។

យ. ម្នាលអាវុសោសារីបុត្ត កាលគំនិតនេះមានដល់លោកដ៏មានអាយុទាំងឡាយឯណា លោកដ៏មានអាយុទាំងនោះបានឈ្មោះថាជា

សព្រហ្មចារី ជាអ្នកអនុគ្រោះ បង់ឲ្យបានប្រយោជន៍ ជាអ្នកឲ្យឱវាទ ជាអ្នកប្រៀនប្រដៅ (ឥឡូវ) ចិត្តរបស់ខ្ញុំបានរួចផុត ស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់មាំ (ដោយឧបាទាន) ព្រោះបានស្តាប់ព្រះធម្មទេសនា របស់ព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះឯង ។

ចប់សេចក្តីបុច្ឆាវិសជ្ជនា របស់ព្រះថេរទាំងពីររូបតែប៉ុណ្ណេះ បើយើងគិតពិនិត្យ តាមដំណើរធម្មសាកច្ឆាដែលពោលមកនេះ នឹងឃើញថាចង្អៀតយល់ ចង្អៀតស្តាប់បន្តិច ប៉ុន្តែល្មមឲ្យមើលឃើញដំរុយដែលនៅឆ្ងាយលង្វឹមនោះបានខ្លះហើយ ទុកជាមិនច្បាស់លាស់ ក៏ល្មមឲ្យយល់បានថា យោបល់របស់ព្រះអរហន្តវែងឆ្ងាយនឹងយោបល់របស់បុថុជ្ជនជាដរាប សម្បត្តិសួគ៌និងសម្បត្តិមនុស្សលោកដែលប្រកបនឹងកាមគុណទាំង ៥ ប្រការជាដើម បុថុជ្ជនតែងយល់ថាជាតួសុខសប្បាយ សឹងប្រាថ្នាចង់បានកល់គ្នា តែព្រះអរិយៈយល់ថាជាតួទុក្ខ មិនទៀង មានសេចក្តីប្រែប្រួល មិននៅក្នុងអំណាចរបស់បុគ្គលណាមួយឡើយ បច្ច័យតាក់តែងឲ្យកើតឡើងៈហើយ ក៏ប្រែប្រួលរលត់រលាយបាត់ទៅវិញជាធម្មតា មិនផុតអំពីជាតិ ជរា ព្យាធិ មរណៈទៅបាន ទើបគួរនឿយណាយគួរស្អប់ខ្ពើមគួរលះបង់ទាំងអស់ មានតែព្រះនិព្វានមួយទេ ដែលជាសុខដ៏ពិតប្រាកដទៀងទាត់មិនប្រែប្រួល រកគូរប្រៀបផ្ទឹមគ្មាន ។ (ញ. ឋ.)

# តាំងផាស់មាជិកពិសេសថ្មីពីររូប

## នៃសាលាបាលីជាន់ខ្ពស់នៅក្រុងភ្នំពេញ → 

ពាមប្រកាសលោកអគ្គនាយកនៃប្រទេសឥណ្ឌូចិន ចុះថ្ងៃ ២៧ មីនា ១៩៤៣ តាំងព្រះមហាថេរពីររូបជាសមាជិកពិសេស របស់សាលាបាលីជាន់ខ្ពស់ប្រទេសគឺ:

ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ ជួន - ណាត, ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ។

ព្រះតេជព្រះគុណព្រះសាក្យវង្ស ហួត - តាត, អាចារ្យបង្រៀនសំស្ក្រឹត នៅសាលាបាលីជាន់ខ្ពស់ ។

*

* *

# អ្នករាជការនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ

## បានទទួលព្រះរាជទានបណ្ដាស័ក្តិ

តាមព្រះក្រឹត្យលេខ ២៥ ចុះថ្ងៃ ៥ មីនា ១៩៤៣ ព្រះបាទសម្តេចព្រះនរោត្តម- សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់ព្រះករុណាប្រោសព្រះរាជទានបណ្តាស័ក្តិកិត្តិយស ដល់អ្នករាជការ ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ ដូចមាននាមឈ្មោះខាងក្រោមនេះគឺ:

១- លោកហ្លួង យៀន - ប៊ីម, ចាងហ្វាងរង ជាទីព្រះនាយកមន្ត្រី ស័ក្តិ ៦ ហ៊ូពាន់ ។

២- លោកស្មៀន គង់ - ជា, ជាទីហ្លួងរតនានុរ័ក្សន៍ ស័ក្តិ ៥ ហ៊ូពាន់ ។

៣- លោកស្មៀន អ៊ុង - ស្បោង, ជាទីបុននសុខុមប្រីជា ស័ក្តិ ៤ ហ៊ូពាន់ ។

៤- ព្រះលេខានុរ័ត ឡាយ - គឹក, ជាទីឧកញ៉ាលេខានុរ័ត ស័ក្តិ ៧ ហ៊ូពាន់ ។

កម្ពុជសុរិយា សូមទទួលអំណរស្មោះត្រង់ សូមជូនពរសព្ទសាធុការ សូមឲ្យអស់លោកបានចំរើនបុណ្យស័ក្តិជាភិយ្យោភាពឡើងតទៅ ។